ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាព

## ស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារ

## ឆ្នាំ២០២៣-២០២៧

រៀបចំដោយ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ឆ្នាំ២០២៣

# អារម្ភកថា

ការថែទាំជំនួស គឺជាផ្នែកមួយដ៏សំខាន់នៃការផ្តល់សេវាចំពោះកុមាររងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទដែលរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៦។ ដើម្បីអនុវត្តគោលនយោបាយនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅក្នុងមណ្ឌលឆ្នាំ២០០៦ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ឆ្នាំ២០០៨ ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០១១ ប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ឆ្នាំ២០២២ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត។ ទន្ទឹមនេះដើម្បីកំណែទម្រង់វិស័យថែទាំជំនួសនៅកម្ពុជា រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ" ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍" ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ ជាមួយនឹងការប្តេជ្ញាចិត្តនេះឆ្លុះបញ្ចាំង នូវអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលទទួលស្គាល់នូវសារសំខាន់នៃគ្រួសារថាជាមជ្ឈដ្ឋានធម្មជាតិសម្រាប់ការធំលូតលាស់ ការអភិវឌ្ឍ និងសុខភាពរបស់កុមារ។

ដើម្បីបង្កើនកិច្ចសហការអនុវត្តគោលនយោបាយខាងលើឱ្យប្រសិទ្ធភាពបន្ថែមទៀត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានរៀបចំផែនការសកម្មភាពស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៣-២០២៧ គឺដើម្បីពង្រឹងការថែទាំជំនួសចំពោះកុមារ តាមរយៈការលើកកម្ពស់ការរក្សាកុមារក្នុងគ្រួសារ ការថែទាំកុមារដោយសាច់ញាតិ ឬឪពុកម្តាយធម៌ និងសមាហរណកម្មកុមារ ទៅកាន់គ្រួសារ និងសហគមន៍ ព្រមទាំងកែសម្រួលគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីពង្រឹងគុណភាព និងការគ្រប់គ្រងសេវាថែទាំជំនួសចំពោះកុមារដែលផ្តោតអាទិភាពលើគោលដៅចំនួនបួនគឺ៖(១)ពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារ (២)ពង្រឹងការគ្រប់គ្រង និងគុណភាពសេវាថែទាំជំនួសចំពោះកុមារ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍ (៣)ពង្រឹងកម្មវិធីរក្សាកុមារក្នុងគ្រួសារ និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ និង (៤)ពង្រឹងកិច្ចសហប្រតិបត្តិការសម្របសម្រួល និងពិនិត្យតាមដានការងារថែទាំជំនួស និងកិច្ចការពារកុមារ។

ខ្ញុំសូមកោតសរសើរដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គនាយកដ្ឋានសេវាសង្គមកិច្ច នាយកដ្ឋានកិច្ចការពារកុមារ នាយកដ្ឋានជំនាញ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត យូនីសេហ្វ អង្គការមិនមែនរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ ដែលបានខិតខំចូលរួមកសាងផែនការសកម្មភាពស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៣-២០២៧នេះ។ ទន្ទឹមនឹងនេះខ្ញុំជឿជាក់យ៉ាងមុតមាំ ថា គ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងអនុវត្តផែនការសកម្មភាពនេះ ឱ្យទទួលបានជោគជ័យប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធផល។

ថ្ងៃ ពុធ ៩រោច ខែ ផល្គុន ឆ្នាំខាល ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៣

រដ្ឋមន្ត្រី

វង សូត

# មាតិកា


**អារម្ភកថា** ........ i

**មាតិកា** ........ iii

**អក្សរកាត់** ........ iv

**១. សេចក្តីផ្តើម** ........ ១

**១.១. សាវតា** ........ ១

**១.២. គោលការណ៍សំខាន់ៗ** ........ ២

១.២.១.គោលការណ៍នៃការថែទាំជំនួស ........ ២

១.២.២.ឧត្តមប្រយោជន៍របស់កុមារ ........ ២

១.២.៣.ការមិនបង្កឱ្យមានការឈឺចាប់បន្ថែម ........ ៣

១.២.៤.សមធម៌ ........ ៣

**១.៣. ការរក្សា និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់** ........ ៣

**២. វឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ** ........ ៤

**២.១. វឌ្ឍនភាព** ........ ៤

**២.២. បញ្ហាប្រឈម** ........ ៦

**២.៣. ដំណោះស្រាយ** ........ ៦

**៣. ទំនាក់ទំនងជាមួយនឹងផែនការផ្សេងទៀត** ........ ៧

**៤. គោលដៅ** ........ ៧

**គោលដៅទី១៖** ពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារ ........ ៨

**គោលដៅទី២៖** ពង្រឹងការគ្រប់គ្រង និងគុណភាពសេវាថែទាំជំនួសចំពោះកុមារ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍ ........ ៩

**គោលដៅទី៣៖** ពង្រឹងកម្មវិធីរក្សាកុមារក្នុងគ្រួសារ និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ ........ ១០

**គោលដៅទី៤៖** ពង្រឹងកិច្ចសហប្រតិបត្តិ ការសម្របសម្រួល និងពិនិត្យតាមដានការងារថែទាំជំនួស និងកិច្ចការពារកុមារ ........ ១១

**៥. ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការសកម្មភាព** ........ ១២

**៦. យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន និងតម្រូវការថវិកា** ........ ១២

**៦.១. យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន** ........ ១២

**៦.២. តម្រូវការថវិកាសម្រាប់អនុវត្តផែនការសកម្មភាព** ........ ១២

**៧. សេចក្តីសន្និដ្ឋាន** ........ ១៣

**ឧបសម្ព័ន្ធ** ........ ១៤

# អក្សរកាត់

| | |
|---|---|
| **គ.ក.ស.ក** | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| **គ.ក.ន.ក** | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ |
| **ក្រសួង ស.អ.យ** | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **មន្ទីរ ស.អ.យ** | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **យូនីសេហ្វ** | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| **USAID** | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ |
| **VHSG** | ក្រុមទ្រទ្រង់សុខភាពភូមិ |
| **RCIs** | មណ្ឌលថែទាំកុមារ |
| **CRC** | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| **SOP-CP** | សៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ |
| **OSCaR** | ប្រព័ន្ធគ្រប់គ្រងករណីអូស្កា (គ្រប់គ្រងដោយអង្គការ) |
| **Primero** | ប្រព័ន្ធគ្រប់គ្រងករណីកុមារតាមបែបបច្ចេកវិទ្យា (គ្រប់គ្រងដោយរាជរដ្ឋាភិបាល) |
| **CPIMS** | ប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ |
| **CBCPMs** | យន្តការកិច្ចការពារកុមារតាមសហគមន៍ |

# ១. សេចក្តីផ្តើម

## ១.១. សាវតា

ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពការថែទាំជំនួសចំពោះកុមារ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦[១] ដើម្បីអនុវត្តគោលនយោបាយនេះ ក្រសួង ស.អ.យ បានរៀបចំបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល[២] បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍[៣] នីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌[៤] គោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្មកុមារ ការបង្វែរកន្លែងថែទាំ និងការបិទកន្លែងថែទាំកុមារ[៥]។ ទន្ទឹមនេះរាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែស្រួលមាត្រា៧ នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ អនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ" ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍" ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាល ឃុំ។

នៅឆ្នាំ២០១៥ ក្រសួង ស.អ.យ សហការជាមួយអង្គការយូនីសេហ្វ បានចុះស្រាវជ្រាវធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារ បានរកឃើញកន្លែងថែទាំកុមារចំនួន ៦៣៩កន្លែង ដែលមានកុមារ និងយុវជនវ័យក្មេងសរុបចំនួន ៣៥.៣៧៤នាក់ (ស្រី៤៥%) ក្នុងនោះ ២៦.១៨៧នាក់ មានអាយុក្រោម១៨ឆ្នាំ(កុមារី ៤៨%) និងយុវជនវ័យក្មេងចំនួន ៩.១៨៧នាក់។ តាមរយៈការសិក្សានេះ នៅឆ្នាំ២០១៦ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ឱ្យអនុវត្ត "ផែនការពង្រឹងការថែទាំកុមារ និងសមាហរណកម្មកុមារ ចំនួន៣០ភាគរយ ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាព" ពីឆ្នាំ២០១៦-២០១៨។ ជាលទ្ធផលនៃការអនុវត្តផែនការនេះ មណ្ឌលថែទាំកុមារនៅសល់ចំនួន ២៣២ មានកុមារសរុបចំនួន ៦.៧៧៨នាក់ (ស្រី ៣ ៣១៧នាក់) ដូច្នេះ បើធៀបនឹងឆ្នាំ២០១៥ មណ្ឌលថែទាំកុមារបានថយចុះចំនួន ១៧៤កន្លែង (៤៣%) និងកុមាររស់នៅក្នុងមណ្ឌលថែទាំ បានថយចំនួន ៩.៨០១នាក់ (៥៩%)។

យោងតាមរបាយការណ៍នៃការធ្វើអធិការកិច្ចកន្លែងថែទាំកុមារទូទាំងប្រទេសឆ្នាំ២០២២ បានបង្ហាញថា មណ្ឌលថែទាំកុមារមានចំនួន ១៩៤មណ្ឌល មានកុមារសរុបចំនួន ៥.០៧៥នាក់ កុមារី ២.៤៥១នាក់ និងយុវជនវ័យក្មេង (អាយុ ១៨ឆ្នាំឡើង) មានចំនួន ១.២៣៨នាក់ ស្រី ៦២៩នាក់។ ក្នុងនោះមណ្ឌលថែទាំ កុមាររបស់រដ្ឋមានចំនួន ២១មណ្ឌល មានកុមារសរុបចំនួន ៧០៩នាក់ ស្រី ៣០៦នាក់ និងយុវជនវ័យក្មេង(អាយុចាប់ពី ១៨ឆ្នាំឡើង) ចំនួន ៧៦៣នាក់ ស្រី ៤៤៦នាក់។ ដោយឡែក កន្លែងថែទាំបែបសហគមន៍មានចំនួន ១១៨កន្លែង មានកុមារសរុបចំនួន ២.៧៣៨នាក់ កុមារី ១.៤៩១នាក់ និងយុវជនវ័យក្មេង (អាយុ ១៨ឆ្នាំឡើង) មានចំនួន ៧៦៣នាក់ ស្រី ៤៦៦នាក់។

ដើម្បីពង្រឹងគុណភាព និងគ្រប់គ្រងសេវាការថែទាំជំនួស ក្រសួង ស.អ.យ បានរៀបចំផែនការសកម្មភាពស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០២៣-២០២៧ ដោយផ្តោតការលើកកម្ពស់ការរក្សាកុមារក្នុងគ្រួសារ ការថែទាំកុមារដោយសាច់ញាតិ ឬឪពុកម្តាយធម៌ និងសមាហរណកម្មកុមារទៅកាន់គ្រួសារ និងសហគមន៍ ព្រមទាំងកែសម្រួលគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

១. ប្រកាសលេខ២១៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីថែទាំជំនួសចំពោះកុមារ
២. ប្រកាសលេខ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល
៣. ប្រកាសលេខ១៩៨ ស.អ.យ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៨ ស្តីពីបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសគមន៍
៤. ប្រកាសលេខ ១១៩ ស.អ.យ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌
៥. ប្រកាសលេខ ០៣៩ ស.អ.យ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការធ្វើសមារណកម្មការ ការបង្វែរកន្លែងថែទាំ និងការបិទកន្លែងថែទាំកុមារ

## ១.២.គោលការណ៍សំខាន់ៗ

### ១.២.១.គោលការណ៍នៃការថែទាំជំនួស

- គោលការណ៍នៃភាពចាំបាច់ និងភាពសក្តិសមៈ កម្មវិធីថែទាំជំនួសចំពោះកុមារ គឺមានបំណងទប់ស្កាត់ការបំបែកកុមារពីគ្រួសារ (ដោយអនុវត្តតាមគោលការណ៍នៃភាពចាំបាច់) ហើយនៅក្នុងករណីមិនអាចទប់ស្កាត់បានត្រូវធានានូវការផ្តល់ល្អបំផុតដល់កុមារ (ដោយអនុវត្តតាមគោលការណ៍ នៃភាពសក្តិសម)។
- ការទប់ស្កាត់ និងការគាំទ្រគ្រួសារ គឺជាផ្នែកយ៉ាងសំខាន់យុទ្ធសាស្ត្រជារួម សម្រាប់សមាហរណកម្មកុមារ។
- កិច្ចខិតខំប្រឹងប្រែងនានា គប្បីផ្តោតភាគច្រើនទៅដល់ការជួយកុមារឱ្យបន្តស្ថិតនៅជាមួយឪពុកម្តាយ ឬវិលត្រលប់ទៅស្ថិតក្រោមការថែទាំរបស់ឪពុកម្តាយរបស់ពួកគេវិញ ឬនៅពេលចាំបាច់ការថែទាំដោយសមាជិកគ្រួសារជិតៗដទៃទៀត។
- ការដកហូតកុមារចេញពីគ្រួសាររបស់កុមារ គប្បីជាជម្រើសចុងក្រោយ និងសម្រាប់រយៈពេលខ្លីបំផុតតាមអាចធ្វើបាន។
- ស្ថាប័ន និងអង្គការពាក់ព័ន្ធទាំងអស់ ជាពិសេស អ្នកផ្តល់សេវាមានគណនេយ្យភាពចំពោះការធានានូវការថែទាំជំនួសសមស្របចំពោះកុមារជាក្រុមគោលដៅ។
- ការថែទាំជំនួស គប្បីត្រូវបានសម្រេច និងផ្តល់ដោយអ្នកមានវិជ្ជាជីវៈ ដោយផ្អែកទៅតាមករណី និងគប្បីឆ្លើយតបចំពោះឧត្តមប្រយោជន៍របស់កុមារពាក់ព័ន្ធ ដោយពិគ្រោះយោបល់ជាមួយកុមារ។
- កិច្ចខិតខំប្រឹងប្រែងផ្សេងៗគ្នា គប្បីត្រូវបានធ្វើដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើង ដោយផ្អែកលើស្ថានភាពណាមួយរបស់កុមារ ឬឪពុកម្តាយ រួមមាន ភាពក្រីក្រ ជាតិពន្ធុ សាសនា ភេទ ពិការភាពផ្លូវចិត្ត និងផ្លូវកាយ មេរោគអេដស៍/ជំងឺអេដស៍ ឬជំងឺធ្ងន់ធ្ងរដទៃទៀត។
- កុមារតូចៗអាយុក្រោម ៣ឆ្នាំ គប្បីទទួលបានការថែទាំនៅតាមគ្រួសារ។ អាចមានការលើកលែងចំពោះគោលការណ៍នេះ ដើម្បីទប់ស្កាត់ការបំបែកកុមារជាបងប្អូនបង្កើត និងក្នុងករណីដែលការទុកដាក់នេះមានលក្ខណៈជាបន្ទាន់ ឬសម្រាប់រយៈពេលមានកំណត់ ដោយមានការរៀបចំផែនការសម្រាប់សមាហរណកម្មគ្រួសារ ឬដំណោះស្រាយថែទាំរយៈពេលវែងសមស្របដទៃទៀត ជាលទ្ធផលនៃការទុកដាក់នេះ។
- ការថែទាំជំនួសនៅតាមគ្រួសារ មានអាទិភាពលើសពីការថែទាំជំនួសនៅតាមកន្លែងថែទាំកុមារ។ ជម្រើសជំនួសនានា គប្បីត្រូវបានរៀបចំនៅក្នុងបរិបទនៃយុទ្ធសាស្ត្របញ្ចេញកុមារពីមណ្ឌលជារួម ជាមួយនឹងគោលដៅ និងគោលបំណងច្បាស់លាស់ ដែលនឹងអនុញ្ញាតឱ្យមានការលុបបំបាត់កន្លែងថែទាំកុមារបែបនេះជាបណ្តើរៗ។
- កុមារដែលត្រូវការការថែទាំជំនួសត្រូវឆ្លងកាត់ដំណើរការគ្រប់គ្រងករណីស្របតាមសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ (SOP-CP) និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។
- ការរៀបចំកម្មវិធីថែទាំជំនួសនានា គឺជាផ្នែកមួយនៃការពង្រឹងប្រព័ន្ធកិច្ចការពារកុមារជារួម។

### ១.២.២.ឧត្តមប្រយោជន៍របស់កុមារ

គោលការណ៍ឧត្តមប្រយោជន៍របស់កុមារ គឺជាគោលការណ៍គ្រឹះមួយក្នុងចំណោមគោលការណ៍គ្រឹះទាំងបួននៃអនុសញ្ញាស្តីពីសិទ្ធិកុមារ(CRC)។ ឧត្តមប្រយោជន៍របស់កុមារត្រូវតែជាការពិចារណាជាចម្បងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានឥទ្ធិពលលើកុមារ។ ឧត្តមប្រយោជន៍របស់កុមារត្រូវបានធានានៅក្នុងមាត្រា៣ វាក្យខ័ណ្ឌទី១ នៃ CRC ដែលចែងថាៈ នៅក្នុងវិធានការទាំងអស់ពាក់ព័ន្ធនឹងកុមារ ទោះជាធ្វើឡើងដោយស្ថាប័នសាធារណៈ ឬឯកជនដែលទទួលបន្ទុកការងារសុខុមាលភាពសង្គម តុលាការ អាជ្ញាធររដ្ឋបាល ឬអង្គភាពនីតិបញ្ញត្តិផ្សេងទៀតក៏ដោយ ឧត្តមប្រយោជន៍របស់កុមារត្រូវតែជាការយកចិត្តទុកដាក់ចម្បង។ ការអនុវត្តយ៉ាងពេញលេញនូវទស្សនទាននៃឧត្តមប្រយោជន៍របស់កុមារ ទាមទារនូវការរៀបចំអភិក្រម ដែលឈរលើមូលដ្ឋាននៃសិទ្ធិ និងការបង្កការចូលរួមរបស់តួអង្គទាំងអស់ ដើម្បីធាននូវសុចរិតភាពផ្នែករាងកាយ ចិត្តសាស្ត្រ សីលធម៌ និងស្មារតីគ្រប់ជ្រុងជ្រោយចំពោះកុមារ និងលើកកម្ពស់សេចក្តីថ្លៃថ្នូរ ការរស់រានមានជីវិត និងការអភិវឌ្ឍរបស់កុមារ ដូចមានចែងនៅក្នុងមាត្រា ៦ នៃ UNCRC។ ទស្សនទាននេះមានលក្ខណៈស្មុគស្មាញ ហើយខ្លឹមសាររបស់វាត្រូវកំណត់ទៅតាមករណីជាក់ស្តែង។ ខ្លឹមសារនៃទស្សនទាននេះ គប្បីមានការកែសម្រួល និងកំណត់និយមន័យទៅតាមស្ថានភាព

ជាក់លាក់របស់កុមារ ដោយពិចារណាលើបរិបទ ស្ថានភាព និងតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។[៦]

### ១.២.៣.ការមិនបង្កឱ្យមានការឈឺចាប់បន្ថែម

រាល់ការទុកដាក់កុមារនៅក្នុងការថែទាំជំនួស ត្រូវធ្វើឡើងដោយផ្ដល់នូវអត្ថប្រយោជន៍ និងមិនបង្កឱ្យមានការឈឺចាប់បន្ថែមដល់កុមារ ក្នុងនោះរាប់បញ្ចូលទាំងការពិចារណាលើបញ្ហានានា ដូចជា ការបង្ការកុមារពីការរលោភបំពានផ្សេងៗ និងការមាក់ងាយ ការទទួលបានការព្រមព្រៀង និងការរក្សាការសម្ងាត់។ អង្គភាពពាក់ព័ន្ធទាំងអស់គួរតែធ្វើការប៉ាន់ប្រមាណឱ្យបានត្រឹមត្រូវ ដើម្បីកំណត់ឱ្យឃើញ និងកាត់បន្ថយនូវហានិភ័យនានាដែលកើតមានចំពោះកុមារពាក់ព័ន្ធនឹងការថែទាំកុមារ។

### ១.២.៤.សមធម៌

រាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ដើម្បីលើកកម្ពស់ការទុកដាក់កុមារនៅតាមគ្រួសារ និងសហគមន៍ប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាព ត្រូវតែផ្អែកលើសិទ្ធិពេញលេញនានាដែលមានចែងនៅក្នុងអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងច្បាប់ជាតិពាក់ព័ន្ធ។ កុមារគ្រប់រូបទទួលបានសិទ្ធិជាមូលដ្ឋានរបស់ពួកគេដោយមិនគិតពីអាយុ ភេទ ជាតិ សាសន៍ សាសនា ប្រាក់ចំណូល ប្រភេទពិការភាព ទីតាំងភូមិសាស្ត្រ សមត្ថភាព ឬស្ថានភាពផ្សេងទៀតរួមទាំងបញ្ហាអាកប្បកិរិយា និងដោយគ្មានការរើសអើង។ កុមារគ្រប់រូបមានសិទ្ធិចូលរួមក្នុងរាល់ការធ្វើសេចក្ដីសម្រេចចិត្តទាំងអស់ដែលប៉ះពាល់ដល់ពួកគេ ដូច្នេះការសម្រេចចិត្តទាក់ទងនឹងការទុកដាក់ក្នុងការថែទាំជំនួស ត្រូវធ្វើឡើងដោយតម្កល់ឧត្តមប្រយោជន៍របស់ពួកគេជាធំ។

## ១.៣. ការរក្សា និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់

**ដើម្បីរក្សា និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ ត្រូវមានវិធានការដូចខាងក្រោម៖**

- បង្កើតក្រុមការងារសម្រាប់ការទប់ស្កាត់ និងការរក្សាគ្រួសារ។
- រៀបចំ និងធ្វើការផ្សព្វផ្សាយសៀវភៅណែនាំស្ដីពីកិច្ចការពារកុមារសម្រាប់អ្នកស្ម័គ្រចិត្តសហគមន៍ គ.ក.ន.ក និងក្រុមទ្រទ្រង់សុខភាពភូមិ (VHSG) ។
- រៀបចំសម្ភារៈព័ត៌មាន និងទំនាក់ទំនងស្ដីពីការបំបែកកុមារពីគ្រួសារដោយមិនចាំបាច់ដែលត្រូវបញ្ចូលក្នុងគោលនយោបាយភូមិឃុំមានសុវត្ថិភាព។
- កំណត់អត្តសញ្ញាណកុមារ និងគ្រួសារដែលប្រឈមនឹងហានិភ័យ នៃការបំបែកចេញពីគ្រួសារ តាមរយៈការរៀបចំផែនទីសេវាសង្គម។
- ផ្ដល់សេវារក្សាគ្រួសារ និងសេវាទប់ស្កាត់ដល់កុមារ។
- បញ្ជូនកុមារ និងគ្រួសារដែលមានហានិភ័យនៃការបំបែកចេញពីគ្រួសារទៅកាន់សេវាសមស្របរួមមាន ប៉ុស្ដិ៍នគរបាលកិច្ចការពារកុមារឃុំសង្កាត់ (ដែលនឹងត្រូវបង្កើតឡើង) និងសេវាកិច្ចការពារកុមារដទៃទៀត ។
- អនុវត្តកម្មវិធីការចិញ្ចឹមកូនបែបវិជ្ជមាន និងអ្នកថែទាំងាយរងគ្រោះ ព្រមទាំងសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ ដែលផ្ដល់ការថែទាំដល់កុមារសមាហរណកម្មពីកន្លែងថែទាំកុមារ។
- លើកកម្ពស់ការរក្សាគ្រួសារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារតាមរយៈអាជ្ញាធរមូលដ្ឋាន ព្រះសង្ឃ និងអ្នកដឹកនាំសាសនាដទៃទៀត។
- ពង្រីកយុទ្ធនាការគ្រួសាររឹងមាំ នៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT) ទៅកាន់ខេត្តគោលដៅដទៃទៀត ដើម្បីទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។
- គ្មានការបើកមណ្ឌលថែទាំកុមារថ្មីឡើយ។ ក្នុងករណីមិនចាំបាច់ ការបើក និងការអនុញ្ញាតឱ្យដំណើរការមណ្ឌលថែទាំកុមារថ្មីសម្រាប់ថែទាំកុមារ ត្រូវបានយកមកពិចារណាក្នុងការហាមឃាត់។
- ណែនាំមណ្ឌលថែទាំកុមារដែលមានស្រាប់មិនគួរបង្កើនចំនួនគ្រែសម្រាប់កុមារឡើយ។

៦. ឯកសារអនុវត្តជាក់ស្ដែងសម្រាប់កិច្ចការពារកុមារ៖ គន្លឹះទី១ - ការអនុវត្តគោលការណ៍ "ឧត្តមប្រយោជន៍របស់កុមារ" និង "ការមិនបង្កការឈឺចាប់" ដើម្បីគាំទ្រសមាហរណកម្មកុមារពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារនិងសហគមន៍

- សម្រាប់កុមារអាយុក្រោម៣ឆ្នាំ ត្រូវស្វែងរកជម្រើសនៃការថែទាំជំនួសនៅតាមគ្រួសារឱ្យអស់លទ្ធភាព មុននឹងសម្រេចចិត្តទុកដាក់នៅក្នុងមណ្ឌលថែទាំជំនួស។
- ផ្តល់ការថែទាំនៅតាមគ្រួសារ (ការថែទាំដោយសាច់ញាតិ ការថែទាំដោយឪពុកម្តាយធម៌) ជាជម្រើសអាទិភាព ហើយការថែទាំកុមារនៅក្នុងមណ្ឌលជាម្រើសចុងក្រោយ។

## ២. វឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ

### ២.១. វឌ្ឍនភាព

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានកិច្ចសហការ និងការគាំទ្រពីអង្គការដៃគូ បាននិងកំពុងដឹកនាំរួមក្នុងការរៀបចំប្រព័ន្ធកិច្ចការពារ និងការថែទាំកុមារដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងលក្ខណៈបរិយាប័ន្ន។ ការងារគ្រឹះដ៏សំខាន់ត្រូវបានអនុវត្ត ដើម្បីគាំទ្រអភិក្រមពង្រឹងប្រព័ន្ធសម្រាប់កំណែទម្រង់ការថែទាំ។ ការងារទាំងនេះរួមមាន៖

- បាននឹងកំពុងគ្រប់គ្រងករណីកុមារនៅក្នុងកន្លែងថែទាំជំនួស (ការចុះឈ្មោះកុមារទាំងអស់ដែលនៅក្នុងកន្លែងថែទាំកុមារទៅក្នុងប្រព័ន្ធ Primero ក្នុងគោលបំណងដើម្បីផ្តល់សេវាគ្រប់គ្រងករណី)។
- ការដាក់ឱ្យអនុវត្ត និងពង្រឹងប្រព័ន្ធអធិការកិច្ច និងគ្រប់គ្រងករណីតាមបែបបច្ចេកវិទ្យា។
- ការងារត្រៀម ដើម្បីបង្កើនការវិនិយោគនៅក្នុងការអភិវឌ្ឍកម្លាំងសេវាសង្គមដែលចាំបាច់ ក្នុងការផ្តល់អន្តរាគមន៍ផ្នែកគាំពារសង្គម និងកិច្ចការពារកុមារ។
- ការបង្កើតផែនការកសាងសមត្ថភាព និងគោលការណ៍ណែនាំ ដើម្បីបង្កើនការរក្សាគ្រួសារ និងការថែទាំកុមារតាមគ្រួសារ។
- ការរៀបចំនិងការធ្វើការងារលើការផ្សព្វផ្សាយ និងការដាក់ឱ្យអនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ និងទម្រង់បែបបទសម្រាប់អនុវត្តប្រកាសនេះ។
- បានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្មកុមារ ការបង្វែរកន្លែងថែទាំ និងការបិទកន្លែងថែទាំកុមារ។
- បានផ្សព្វផ្សាយ និងជំរុញការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារ ប្រកាសស្តីពីនីតិវិធីអនុវត្តនៃការថែទាំជំនួសចំពោះកុមារ និងបានបណ្តុះបណ្តាលណែនាំអំពីការគ្រប់គ្រងករណីកុមារ និងតួនាទីនិងភារកិច្ចរបស់មន្ត្រីបង្គោល នៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌទាំងអស់។
- បាននឹងកំពុងរៀបចំសេចក្តីព្រាងសៀវភៅណែនាំ ស្តីពីនីតិវិធីអនុវត្តសុំកូនក្នុងប្រទេសសម្រាប់មន្ត្រីសង្គមកិច្ច។
- បាននឹងកំពុងពិនិត្យ និងកែសម្រួលឡើងវិញនូវគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០០៦ ឱ្យស្របនឹងស្ថានភាពសេដ្ឋកិច្ចសង្គម ច្បាប់និងគោលនយោបាយរបស់កម្ពុជានាពេលបច្ចុប្បន្ន និងស្របតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការថែទាំជំនួសចំពោះកុមារ។
- បានធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងករណីកុមារ Primero ជំនាន់ទី២ ព្រមទាំងបានបណ្តុះបណ្តាល អំពីការប្រើប្រាស់ប្រព័ន្ធនេះដល់មន្ត្រីបង្គោល និងបុគ្គលិកសង្គម នៃមន្ទីរ ស.អ.យ ព្រមទាំងមន្ត្រីបង្គោលនៃការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាំង ២៥ រាជធានី ខេត្ត។
- បាននិងកំពុងពិនិត្យ និងកែសម្រួលឯកសារពាក់ព័ន្ធឡើងវិញពាក់ព័ន្ធនឹងគណៈកម្មការគុណវុឌ្ឍិ សម្រាប់អង្គការសុវត្ថិភាពកុមារ ដូចជា បទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារ ប្រកាសស្តីពីក្រមសីលធម៌សម្រាប់កិច្ចការពារកុមារ សៀវភៅបណ្តុះបណ្តាលស្តីពីអង្គការសុវត្ថិភាពកុមារ និងប្រកាស ស្តីពីការបង្កើតគណៈកម្មការដឹកនាំ និងគ្រប់គ្រងគុណវុឌ្ឍិនៃអង្គការសុវត្ថិភាពកុមារ។
- បានសហការជាមួយក្រសួងមហាផ្ទៃរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦ និងសម្របសម្រួលរៀបចំផែនការប្រតិបត្តិស្តីពីកិច្ចការពារកុមារតាមរាជធានី ខេត្ត។
- បាននឹងកំពុងសហការជាមួយក្រសួងមហាផ្ទៃ រៀបចំសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់

រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- បាននឹងកំពុងសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ ដើម្បីសិក្សា និងធ្វើការគ្រប់គ្រងករណីកុមារដែលរស់នៅជាមួយម្ដាយក្នុងពន្ធនាគារមានអាយុលើ៣ឆ្នាំ ផ្ដល់សេវាថែទាំជំនួស និងកិច្ចការពារ។
- បានបើកយុទ្ធនាការគ្រួសាររឹងមាំ ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងការលុបបំបាត់អំពើហិង្សាលើកុមារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់នៅកម្ពុជា និងរៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលថ្នាក់ក្រោមជាតិស្ដីពីគ្រួសាររឹងមាំសម្រាប់ក្រុមឪពុកម្ដាយ នៅតាមរាជធានី ខេត្ត គោលដៅ។
- បានបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ (CPIMS) ដែលមានកំណត់សូចនាករសម្រាប់វិស័យកិច្ចការពារកុមារ។

ក្រសួងបានដាក់អនុវត្តផែនការសកម្មភាពដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន៣០ភាគរយ ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសាររបស់ពួកគេវិញដោយសុវត្ថិភាព ឆ្នាំ២០១៦-២០១៨ ដែលជាក្របខណ្ឌការងារជាយុទ្ធសាស្ត្រ ក្នុងការដឹកនាំកិច្ចខិតខំប្រឹងប្រែងកែទម្រង់ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល។ ជាលទ្ធផលនៃការអនុវត្តផែនការនេះ មណ្ឌលថែទាំកុមារនៅសល់ចំនួន ២៣២ មានកុមារសរុបចំនួន ៦.៧៧៨នាក់ (ស្រី ៣.៣១៧នាក់) ដូច្នេះ បើធៀបនឹងឆ្នាំ២០១៥ មណ្ឌលថែទាំកុមារបានថយចុះ ចំនួន ១៧៤កន្លែង (៤៣%) និងកុមាររស់នៅក្នុងមណ្ឌលថែទាំបានថយចំនួន ៩.៨០១នាក់ (៥៩%)។ ក្នុងចំណោម ១៧៤មណ្ឌល មានមណ្ឌលថែទាំកុមារចំនួន ២៤មណ្ឌលបានបង្វែរទៅជាសេវាថែទាំកុមារតាមសហគមន៍ មណ្ឌលថែទាំកុមារចំនួន ៧៣មណ្ឌល បានផ្លាស់ទៅជាសេវាថែទាំដែលពុំមែនជាមណ្ឌលថែទាំ និងមណ្ឌលកុមារចំនួន ៧៧ មណ្ឌលថែទាំកុមារបានបិទ ក្នុងនោះ ២មណ្ឌលត្រូវបានបិទ ដោយសារតែអនុវត្តក្រោមបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារធ្ងន់ធ្ងរនិង៧៥មណ្ឌលផ្សេងទៀត ត្រូវបានបិទដោយសារមិនមានហិរញ្ញវត្ថុគ្រប់គ្រាន់ ម្ចាស់ជំនួយលែងបន្តគាំទ្រ និងហេតុផលផ្សេងៗទៀត។ កុមារចំនួន ១.៤១៩នាក់ ស្មើនឹង ១២ភាគរយ ធៀបនឹងកុមារចំនួន ១១.៧៨៨នាក់ រស់នៅក្នុងមណ្ឌលថែទាំនៅក្នុងរាជធានី ខេត្ត គោលដៅទាំង៥ ត្រូវបានជួយគាំទ្រដើម្បីសមាហរណកម្ម។ យោងតាមប្រព័ន្ធទិន្នន័យត្រួតពិនិត្យតាមដានកុមារសមាហរណកម្ម (Child Tracking Tool) ស្ថានភាពរបស់កុមារមានដូចខាងក្រោម៖

- កុមារចំនួន ១.០២១នាក់ (៧៥%) មានស្ថានភាពពណ៌បៃតង (កុមារមានសុវត្ថិភាព និងស្ថិរភាព)។
- កុមារចំនួន ៧៨ (៦%) មានស្ថានភាពពណ៌លឿង (កុមារស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់តាមដានបន្ថែម)។
- កុមារចំនួន ៣៤នាក់ (៣%) មានពណ៌ក្រហម (កុមារស្ថិតក្នុងស្ថានភាពរងគ្រោះ ដែលតម្រូវឱ្យធ្វើការប៉ាន់ប្រមាណឡើងវិញ ដើម្បីកំណត់ហានិភ័យ និងស្វែងរកសេវាចាំបាច់សម្រាប់កុមារ និងគ្រួសារ)។
- ១៩៩នាក់បានធ្វើចំណាកស្រុកតាមគ្រួសារ ឬផ្លាស់ប្ដូរទីលំនៅដែលនាំឱ្យបាត់ព័ត៌មានដូច្នេះកុមារទាំងនេះមិនទាន់ត្រូវបានធ្វើបច្ចុប្បន្នភាពនៅឡើយទេ តែទោះជាយ៉ាងណាក៏ដោយមន្ត្រីបង្គោល និងបុគ្គលិកសង្គម នៅតែបន្តតាមដាន និងស្រាវជ្រាវបន្ថែមទៀត ដើម្បីធ្វើឱ្យកុមារទាំងនោះមានសុវត្ថិភាពតាមគោលការណ៍របស់ក្រសួង។
- និងកុមារចំនួន ៨៧នាក់ទៀត មិនទាន់ត្រូវបានធ្វើបច្ចុប្បន្នភាពទេ ដោយមូលហេតុកុមារទើបតែត្រូវបានបង្រួបបង្រួម ឬទុកដាក់។ មន្ត្រីបង្គោល និងបុគ្គលិកសង្គម បន្តធ្វើបច្ចុប្បន្នស្ថានភាពរបស់ កុមារទាំងនេះនៅឆ្នាំ២០២០។

ផ្អែកតាមទិន្នន័យអធិការកិច្ចកន្លែងថែទាំកុមារទូទាំងប្រទេសឆ្នាំ២០២២ បានបង្ហាញថា មណ្ឌលថែទាំកុមារ មានចំនួន ១៩៤មណ្ឌល មានកុមារសរុបចំនួន ៥.០៧៥នាក់ កុមារី ២.៤៥១នាក់ និងយុវជនវ័យក្មេង (អាយុ ១៨ឆ្នាំឡើង) មានចំនួន ១.២៣៨នាក់ ស្រី ៦២៩នាក់។ ក្នុងនោះមណ្ឌលថែទាំកុមាររបស់រដ្ឋមានចំនួន ២១មណ្ឌល មានកុមារសរុបចំនួន ៧០៩នាក់ ស្រី ៣០៦នាក់ និងយុវជនវ័យក្មេង (អាយុចាប់ពី ១៨ឆ្នាំឡើង) ចំនួន ៧៦៣នាក់ ស្រី ៤៤៦នាក់។ ដោយឡែកកន្លែងថែទាំបែបសហគមន៍មានចំនួន ១១៨កន្លែង មានកុមារសរុបចំនួន ២.៧៣៨នាក់ កុមារី ១.៤៩១នាក់ និងយុវជនវ័យក្មេង (អាយុ ១៨ឆ្នាំឡើង) មានចំនួន ៧៦៣នាក់ ស្រី ៤៦៦នាក់។

## ២.២.បញ្ហាប្រឈម

ស្របពេលដែលមានការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លាចំពោះកំណែទម្រង់នៃការថែទាំកុមារ និងការសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្តី ដំណើរការកសាងប្រព័ន្ធកិច្ចការពារ និងថែទាំកុមារមិនទាន់បានសម្រេចតាមគោលដៅទាំងស្រុងនៅឡើយទេ។ កំណែទម្រង់ច្បាប់ និងគោលនយោបាយមិនទាន់មានលក្ខណៈសុខដុមនីយកម្ម និងនៅមានភាពភ័ន្តច្រឡំនៅជុំវិញនីតិវិធី តួនាទី និងការទទួលខុសត្រូវនានា។ បន្ថែមពីនេះ យន្តការសម្របសម្រួលនៅមានភាពខ្វះចន្លោះពាក់ព័ន្ធនឹងបែងចែកមុខងារ និងការទទួលខុសត្រូវផ្នែកកិច្ចការពារកុមារ។ ការផ្ទេរមុខងារ និងថវិកាពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការនៅមានបញ្ហាប្រឈមដែលធ្វើឱ្យការឆ្លើយតបទៅនឹងការងារកិច្ចការពារកុមារ នៅមិនទាន់ល្អប្រសើរស្របតាមស្មារតីនៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ" ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍" ទៅឱ្យរដ្ឋបាល រាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។

គោលដៅប្រកបដោយមហិច្ឆិតានានាត្រូវបានកំណត់សម្រាប់សមាហរណកម្ម ប៉ុន្តែមិនទាន់សម្រេចបាននៅក្នុងរយៈពេលដំបូងដែលមានកំណត់នៅក្នុងផែនការសកម្មភាព ដោយសារកង្វះនីតិវិធីសម្រាប់សមាហរណកម្ម និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការធ្វើសមាហរណកម្ម និងយន្តការតាមដានត្រួតពិនិត្យលើកុមារដែលបានសមាហរណកម្ម ជាលទ្ធផល ការអនុវត្តផែនការនេះ បានបង្ហាញនូវភាពខុសគ្នាទាក់ទងនឹងគុណភាពនៃដំណើរការសមាហរណកម្ម និងក្តីបារម្ភទាក់ទងនឹងភាពសមស្រប និងភាពគ្រប់គ្រាន់នៃសេវាគាំទ្រដែលផ្តល់ដល់កុមារ និងគ្រួសារ។

ការផ្លាស់ប្តូរឥរិយាបទសាធារណជនទូទៅ ជាពិសេសឪពុកម្តាយ ដែលគិតថាការទុកដាក់កុមារថែទាំក្នុងមណ្ឌលជាជម្រើសល្អ ដែលជាហេតុធ្វើឱ្យការជំរុញ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍ និងការទប់ស្កាត់ និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ នៅមានបញ្ហាប្រឈម។ ទន្ទឹមនឹងនេះ សមត្ថភាព បទពិសោធន៍ និងគុណភាពនៃការផ្តល់សេវាសង្គមនៅថ្នាក់មូលដ្ឋាន នៅតែជាឧបសគ្គចំពោះការពង្រឹងប្រព័ន្ធកិច្ចការពារ និងការថែទាំកុមារ។ កង្វះការគ្របដណ្តប់ថ្នាក់ជាតិនៃសេវាសុខុមាលភាពកុមារ និងគ្រួសារសំខាន់ៗ និងរបបគាំពារសង្គមនៅមានកម្រិត រួមជាមួយនឹងសេវារបស់អង្គការមិនមែនរដ្ឋាភិបាលមានទំហំតូចៗ និងផ្តោតលើតំបន់គោលដៅរៀងៗខ្លួន បង្កឱ្យមានការគាំទ្រ និងលទ្ធផលខុសគ្នាស្រឡះសម្រាប់កុមារ។ ហានិភ័យនេះមានលក្ខណៈគួរឱ្យកត់សម្គាល់ចំពោះកុមារមានពិការភាព កុមារមានតម្រូវការពិសេស និងកុមារមកពីសហគមន៍ដាច់ស្រយាល ដែលតម្រូវការរបស់ពួកគេមិនត្រូវបានចាត់ជាអាទិភាព និងមិនសមស្របតាមគោលការណ៍សមធម៌។

ភាពមិនប្រាកដប្រជានៃប្រព័ន្ធមូលដ្ឋានទិន្នន័យថ្នាក់ជាតិជាក់លាក់ស្តីពីកុមាររងគ្រោះ និងងាយរងគ្រោះបានបង្កឱ្យភាពរាំងស្ទះក្នុងការប្រើប្រាស់សម្រាប់ធ្វើការវិភាគ និងកំណត់អាទិភាពកិច្ចការពារកុមារ ខណៈពេលដែលប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ កំពុងស្ថិតក្នុងដំណើរការ។ ជាមួយគ្នានេះ ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងករណីតាមបច្ចេកទេស Primero នៅមិនទាន់ដំណើរការដោយរលូន ដោយសារកត្តាខ្វះធនធានមនុស្សក្នុងការគ្រប់គ្រង និងការប្រើប្រាស់ចំណេះដឹងផ្នែកបច្ចេកវិទ្យា ហើយប្រព័ន្ធនេះនៅមិនទាន់បានបន្សុីគ្នាជាមួយប្រព័ន្ធផ្សេងទៀត ដូចជាប្រព័ន្ធ OSCaR ជាដើម។

## ២.៣.ដំណោះស្រាយ

ដើម្បីដោះស្រាយបញ្ហាខាងលើ ក្រសួង ស.អ.យ ត្រូវសហការជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ យូនីសេហ្វ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធក្នុងការអនុវត្ត ដូចជា ការធ្វើសុខដុមនីយកម្មក្របខណ្ឌច្បាប់ និងគោលនយោបាយពាក់ព័ន្ធទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ រួមទាំងធ្វើការកែសម្រួល និងអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ឱ្យស្របតាមគោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមាររបស់អង្គការសហប្រជាជាតិ និងលិខិតបទដ្ឋានគិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារ។

ពង្រឹងសមត្ថភាព និងគុណភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារ ដោយផ្តោតលើការគ្រប់គ្រងករណី ការធ្វើអធិការកិច្ចកន្លែងថែទាំកុមារឱ្យស្របតាមគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ។ លើកកម្ពស់ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ តាមរយៈការអនុវត្តនីតិវិធីអនុវត្ត ការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ គោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្មកុមារ ការបង្វែរនិងបិទកន្លែងថែទាំកុមារ និងពង្រឹងពង្រីកកម្មវិធីទុកដាក់កុមារជាអចិន្ត្រៃយ៍តាមរយៈសុំកូនក្នុងប្រទេស។ ពង្រឹងសមត្ថភាពការអនុវត្តអនុក្រឹត្យនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ដាក់ឱ្យអនុវត្ត និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងករណីតាមបច្ចេកទេស Primero តាមរយៈការពង្រឹងសមត្ថភាពមន្ត្រីបង្គោល បុគ្គលិកសង្គម និងការបន្សុីគ្នាជាមួយប្រព័ន្ធផ្សេងទៀតដូចជាប្រព័ន្ធ OSCaR ជាដើម។

ពង្រឹងការថែទាំកុមារប្រកបដោយប្រសិទ្ធភាពសម្រាប់ការទប់ស្កាត់ ព្រមទាំងការធានាថា កុមារដែលត្រូវបានបង្រួបបង្រួមគ្រួសារស្ថិតនៅក្នុងបរិយាកាសគ្រួសារប្រកបដោយសុវត្ថិភាព និងការចិញ្ចឹមបីបាច់។ បន្តយុទ្ធនាការគ្រួសាររឹងមាំនៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង(Cambodia PROTECT) និងបណ្តុះបណ្តាលឧបករណ៍ផ្សព្វផ្សាយស្តីពីគ្រួសាររឹងមាំនៅតាមសហគមន៍ អនុវត្តឧបករណ៍កម្រិតទី៣ នៃការចិញ្ចឹមកូនបែបវិជ្ជមាន និងពង្រីកបន្ថែមយុទ្ធសាស្ត្រ INSPIRE ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ បង្កើតក្របខណ្ឌការងារជាក់លាក់សម្រាប់យន្តការកិច្ចការពារកុមារតាមសហគមន៍ (CBCPMs) ដើម្បីទប់ស្កាត់ និងការពារឱ្យបាននៅមុនបញ្ហាកិច្ចការពារកុមារកើតឡើង។

ក្រសួង ស.អ.យ នឹងធ្វើការក្នុងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន យូនីសេហ្វ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តផែនការសកម្មភាពស្តីពីការធ្វើឱ្យប្រសើរនូវការថែទាំជំនួសចំពោះកុមារ និងពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យតាមដានការធ្វើសមាហរណកម្មកុមារ និងការផ្តល់សេវាឆ្លើយតបតាមរយៈការបង្កើតក្រុមការងារថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

## ៣. ទំនាក់ទំនងជាមួយនឹងផែនការផ្សេងទៀត

ផែនការសកម្មភាព ស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៣-២០២៧នេះគឺជាផ្នែកមួយនៃផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦ ដែលនឹងរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ផែនការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩ និងផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារពាក់ព័ន្ធដទៃទៀត។ សកម្មភាពនានានៅក្នុងផែនការសកម្មភាពនេះ នឹងត្រូវផ្សារភ្ជាប់ជាមួយនឹងផែនការប្រតិបត្តិកិច្ចការពារកុមាររាជធានី ខេត្ត នៅពេលមានផែនការរាជធានី ខេត្ត ឬមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងផែនការនៅថ្នាក់ក្រោមជាតិនៅពេលមិនទាន់មានផែនការកិច្ចការពារកុមាររាជធានី ខេត្ត។

## ៤. គោលដៅ

ដើម្បីធ្វើឱ្យដំណោះស្រាយខាងលើទទួលបានជោគជ័យ ក្រសួង ស.អ.យ រៀបចំផែនការសកម្មភាពស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៣-២០២៧ ដោយកំណត់គោលដៅចំនួនបួនគឺ៖ (១)**ពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងការថែទាំជំនួសចំពោះកុមារ** (២)**ពង្រឹងការគ្រប់គ្រង និងគុណភាពសេវាថែទាំជំនួសចំពោះកុមារ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍** (៣)**ពង្រឹងកម្មវិធីរក្សាកុមារក្នុងគ្រួសារ និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ និង**(៤)**ពង្រឹងកិច្ចសហប្រតិបត្តិការសម្របសម្រួល និងពិនិត្យតាមដានការងារថែទាំជំនួស និងកិច្ចការពារកុមារ។** គោលដៅនីមួយៗគាំទ្រដោយគោលបំណងលទ្ធផលរំពឹងទុក និងសកម្មភាពដែលរៀបរាប់លម្អិតដូចខាងក្រោម៖

| | |
|---|---|
| **គោលដៅទី១៖** | ពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារ។ |
| **គោលបំណង៖** | ដើម្បីកែសម្រួល និងបង្កើតគោលនយោបាយរួមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងការថែទាំជំនួសចំពោះកុមារ ដែលឆ្លុះបញ្ចាំងនូវគោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមារ។ |
| **លទ្ធផលរំពឹងទុក៖** | គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារត្រូវបានកែសម្រួល និងអនុម័តនៅឆ្នាំ២០២៧។ |

## សកម្មភាពអនុវត្ត៖

១.១. ពិនិត្យឡើងវិញលើគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ឱ្យស្របតាមគោលការណ៍ណែនាំសម្រាប់ការថែទាំជំនួសចំពោះកុមាររបស់អង្គការសហប្រជាជាតិ និងស្របតាមបរិបទកម្ពុជានាពេលបច្ចុប្បន្ន

១.២. បង្កើត និងអនុវត្តគោលនយោបាយ ឬគោលការណ៍ណែនាំស្តីពីការគាំទ្រដល់គ្រួសារជាលក្ខណៈស្តង់ដារជាតិ ដោយមានផែនការត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់ក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

១.៣. រៀបចំផែនការករណីសម្រាប់កុមារទាំងអស់ដែលកំពុងស្នាក់នៅក្នុងមណ្ឌល (គ្រប់ករណីទាំងអស់ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងករណី Primero) និងផ្តល់សេវាសមាហរណកម្ម

១.៤. កែសម្រួលបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍

១.៥. កែសម្រួលប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

១.៦. ជំរុញការអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

១.៧. ពិនិត្យ និងអនុម័តនីតិវិធីអនុវត្តការសុំកូនក្នុងប្រទេស សម្រាប់បន្ថែមជំពូកទី៧ នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

១.៨. ជំរុញការអនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ និងគោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្មកុមារ ការបង្វែរកន្លែងថែទាំ និងការបិទកន្លែងថែទាំកុមារ

១.៩. ត្រៀមរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ

១.១០. បន្តរៀបចំសៀវភៅណែនាំស្តីពីនីតិវិធីអនុវត្តមុខងារនៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរងក្រុង ស្រុក ខណ្ឌ

១.១១. បង្កើត និងអនុវត្តសាកល្បងបទដ្ឋានអប្បរមានៃសេវាកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលផ្តោតលើបទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ

១.១២. បង្កើតបទដ្ឋានអប្បរមាសម្រាប់ថែទាំ និងកិច្ចការពារកុមារមានពិការភាព

១.១៣. បណ្តុះបណ្តាលគុណវុឌ្ឍិនៃអង្គការសុវត្ថិភាពកុមារ ដល់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល រួមមានបទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារ និងប្រកាសស្តីពីក្រមសីលធម៌សម្រាប់កិច្ចការពារកុមារ។ល។

១.១៤. ធ្វើការវាយតម្លៃទៅលើលទ្ធផលនៃការអនុវត្តបទដ្ឋានអប្បបរមានៃសេវាកិច្ចការពារកុមារ និងពង្រីកឱ្យបានគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស

| | |
|---|---|
| **គោលដៅទី២៖** | ពង្រឹងការគ្រប់គ្រង និងគុណភាពសេវាថែទាំជំនួសចំពោះកុមារ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍។ |
| **គោលបំណង៖** | ដើម្បីលើកកម្ពស់ជម្រើសជំនួសឱ្យការថែទាំកុមារនៅតាមកន្លែងថែទាំ តាមរយៈការថែទាំតាមគ្រួសារ និងសហគមន៍ សម្រាប់កុមារដែលត្រូវការការថែទាំជំនួសដោយ ផ្តោតលើការថែទាំតាមគ្រួសារ។ |
| **លទ្ធផលរំពឹងទុក៖** | ២៥% (១.២៣០នាក់) នៃកុមារដែលត្រូវបានធ្វើសមាហរណកម្មពីកន្លែងថែទាំកុមារទៅកាន់គ្រួសារបង្កើតគ្រួសារសាច់ញាតិ និងគ្រួសារធម៌នៅឆ្នាំ២០២៧ ក្នុងលក្ខណៈមួយប្រកបដោយសុវត្ថិភាព និងដោយអនុវត្តទៅតាមដំណើរការគ្រប់គ្រងករណី។<br>២៥% (៥០) នៃមណ្ឌលថែទាំកុមារត្រូវបាន កាត់បន្ថយនៅឆ្នាំ២០២៧។ |

## សកម្មភាពអនុវត្ត៖

២.១. ពង្រឹងការគ្រប់គ្រងករណីតាមកម្មវិធីសិក្សាសម្រាប់កម្លាំងសេវាសង្គមកិច្ចកម្រិត២ តាមរយៈការពង្រឹងសមត្ថភាព ដល់ថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

២.២. ពង្រឹងការអនុវត្តប្រព័ន្ធ Primero ដែលជាឧបករណ៍គ្រប់គ្រងករណីទៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទាំងអស់ដោយផ្សាភ្ជាប់ទៅនឹងប្រព័ន្ធគ្រប់គ្រងករណីអូស្កា (OSCaR) និងឧបករណ៍គ្រប់គ្រងករណីផ្សេងទៀតដែលអង្គការក្រៅរដ្ឋាភិបាលកំពុងប្រើប្រាស់

២.៣. ពង្រឹងការគ្រប់គ្រង និងពង្រឹងប្រសិទ្ធនៃការអនុវត្តប្រព័ន្ធទិន្នន័យអធិការកិច្ចកន្លែងថែទាំកុមារ និងចាត់វិធានការណ៍ចំពោះកន្លែងថែទាំកុមារដែលមិនគោរពទៅតាមគោលនយោបាយ និងបទដ្ឋានគតិយុត្ត

២.៤. បង្កើត និងដំណើរការប្រព័ន្ធត្រួតពិនិត្យ និងគាំទ្រសម្រាប់ការគ្រប់គ្រងករណីលើករណីកិច្ចការពារកុមារដល់មន្ត្រីរាជការ និងដៃគូអភិវឌ្ឍ ដោយមានការសម្របសម្រួលជាមួយអ្នកជំនាញពីស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដោយរួមទាំងមន្ទីរសង្គមកិច្ចជាអ្នកផ្តល់ការត្រួតពិនិត្យផ្នែកបច្ចេកទេស និងការគាំទ្រ

២.៥. ធ្វើផែនទីថ្នាក់ជាតិស្តីពីសេវាកម្មគាំទ្រគ្រួសារដែលមានស្រាប់

២.៦. ផ្សារភ្ជាប់ការអនុវត្ត និងធនធានពីកញ្ចប់កិច្ចការគាំពារសង្គមជាមួយនឹងគោលនយោបាយ ឬគោលការណ៍ណែនាំស្តីពីការគាំទ្រដល់គ្រួសារ

២.៧. ពង្រឹងការតាមដានត្រួតពិនិត្យ និងគាំទ្របច្ចេកទេសចំពោះករណីកុមាររងគ្រោះនិងងាយរងគ្រោះ

២.៨. ពង្រឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗ ពាក់ព័ន្ធនឹងកិច្ចការពារកុមារ

២.៩. បង្កើនការបញ្ជូនករណីកិច្ចការពារកុមារពីឃុំ សង្កាត់ ទៅក្រុង ស្រុក ខណ្ឌ និងផ្តល់សេវាដល់កុមារនិងគ្រួសារដែលរងគ្រោះ និងងាយរងគ្រោះ

២.១០. បង្កើនចំនួនបុគ្គលិកសង្គមកិច្ចនៅថ្នាក់ក្រុង ស្រុក ខណ្ឌ តាមរយៈការជ្រើសរើសថ្មី ឬការតែងតាំងមន្ត្រីរាជការដែលមានស្រាប់

២.១១. កំណត់អត្តសញ្ញាណកុមារដែលរងគ្រោះនិងងាយរងគ្រោះ និងតម្រូវការរបស់ពួកគេទៅតាមអាយុ និងភេទដើម្បីងាយស្រួលផ្តល់សេវាគាំទ្រ

២.១២. ពង្រឹងការត្រួតពិនិត្យតាមដានការអនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ព្រមទាំងគោលនយោបាយ និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

២.១៣. ផ្តល់សេវាដើម្បីបង្ការ និងទប់ស្កាត់កុមារដែលងាយរងគ្រោះក្នុងការបែកចេញពីគ្រួសារ

២.១៤. បង្កើត និងអនុវត្តយន្តការត្រួតពិនិត្យសម្រាប់អ្នកថែទាំដែលជាឪពុកម្តាយធម៌ សាច់ញាតិ និងអ្នកផ្តល់សេវាសុំកូនយោងតាមគោលនយោបាយ និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

២.១៥. ផ្តល់នូវបណ្តាញសុវត្ថិភាព (ការគាំទ្រជាសាច់ប្រាក់ និងសេវាគាំពារសង្គមផ្សេងទៀត តាមរយៈរាជរដ្ឋាភិបាល និងការកៀរគរធនធាននានាមកពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល)

២.១៦. ផ្តល់ការពង្រឹងសេដ្ឋកិច្ចដល់គ្រួសារ ដោយផ្តោតលើគ្រួសារគោលដៅ ដែលមានកុមារងាយរងគ្រោះ

២.១៧. ផ្តល់ការគាំទ្រឪពុកម្តាយធម៌ និងសាច់ញាតិ ដោយផ្សារភ្ជាប់ពួកគេទៅការគាំទ្រកិច្ចគាំពារសង្គម

២.១៨. ផ្សារភ្ជាប់ប្រព័ន្ធគ្រប់គ្រងករណី Primero និងសេចក្តីព្រាងអនុក្រឹត្យ ដើម្បីគាំទ្រដល់ប្រជាជនដែលងាយរងគ្រោះ ដោយរួមបញ្ចូលទាំងការគាំទ្រដល់គ្រួសារដែលមានកុមារងាយរងគ្រោះ

២.១៩. កំណត់អត្តសញ្ញាណជនរងគ្រោះ និងបញ្ជូនបន្តទៅរកសេវាសង្គមផ្សេងៗដែលចាំបាច់សម្រាប់គ្រួសារ និងកុមារដែលអនុលោមទៅតាមកម្មវិធីផ្ទេរសាច់ប្រាក់ដែលកំពុងអនុវត្តដោយក្រសួង ស.អ.យ

២.២០. ធ្វើការប៉ាន់ប្រមាណស្ថានភាពកុមារដែលកំពុងរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ

២.២១. ផ្តល់ការគាំទ្រផ្នែកគ្រប់គ្រងករណីដល់កុមារដែលបានកំណត់អត្តសញ្ញាណ រួមទាំងការរក្សាពួកគេឱ្យបន្តស្ថិតនៅក្នុងគ្រួសារ ឬសមាហរណកម្មទៅថែទាំក្នុងគ្រួសារ ឬសហគមន៍វិញបើអាចធ្វើទៅបាន

២.២២. សហការជាមួយមណ្ឌលថែទាំកុមារ ដែលមានបំណងធ្វើការបង្វែរកម្មវិធីការថែទាំកុមារក្នុងមណ្ឌលទៅជាការថែទាំតាមបែបសហគមន៍ ឬបិទមណ្ឌលថែទាំ

២.២៣. ពង្រឹង និងពង្រីកការអនុវត្តកម្មវិធីការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ និងការសុំកូន (ក្នុងប្រទេស និងក្រៅប្រទេស) រួមទាំងកុមារមានពិការភាព

២.២៤. ត្រៀម និងបន្សាំកុមារអំពីការរស់នៅក្នុងសហគមន៍មុនពេលចាកចេញពីមណ្ឌលថែទាំ

២.២៥. បន្តតាមដាន និងផ្តល់ការគាំទ្រកុមារដែលចាកចេញពីមណ្ឌលថែទាំ

២.២៦. អនុវត្ត និងធ្វើបច្ចុប្បន្នភាពផែនការកិច្ចការពារកុមារក្នុងគ្រាអាសន្នរបស់ក្រសួង

២.២៧. ផ្តល់ការកសាងសមត្ថភាពដល់អ្នកផ្តល់សេវាដែលពាក់ព័ន្ធទៅនឹងការងារកិច្ចការពារកុមារអំពីស្តង់ដារអប្បបរមានៃការងារកិច្ចការពារកុមារ

| | |
|---|---|
| **គោលដៅទី៣៖** | ពង្រឹងកម្មវិធីរក្សាកុមារក្នុងគ្រួសារ និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។ |
| **គោលបំណង៖** | ពង្រឹងការថែទាំកុមារប្រកបដោយប្រសិទ្ធភាពសម្រាប់ការទប់ស្កាត់ ព្រមទាំងការធានាថា កុមារដែលត្រូវបានបង្រួបបង្រួមគ្រួសារស្ថិតនៅក្នុងបរិយាកាសគ្រួសារប្រកបដោយសុវត្ថិភាព និងការចិញ្ចឹមបីបាច់។ |
| **លទ្ធផលរំពឹងទុក៖** | ៧០% (១១៥៦) នៃចំនួនឃុំ សង្កាត់ ទទួលបានការបណ្តុះបណ្តាលស្តីពីគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ និងកិច្ចការពារកុមារនៅឆ្នាំ២០២៧ |

## សកម្មភាពអនុវត្ត៖

៣.១. បង្កើតគណៈកម្មការ ឬ ក្រុមការងារសម្រាប់ការទប់ស្កាត់ និងការរក្សាគ្រួសារ

៣.២. រៀបចំ និងការផ្សព្វផ្សាយសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់អ្នកស្ម័គ្រចិត្តសហគមន៍ គ.ក.ន.ក និងក្រុមទ្រទ្រង់សុខភាពភូមិ (VHSG)

៣.៣. ពិនិត្យឡើងវិញនូវឯកសារបណ្តុះបណ្តាលការថែរក្សាកុមារក្នុងគ្រួសារដែលមានស្រាប់ និងកំពុងអនុវត្តដោយ

អង្គការមិនមែនរដ្ឋាភិបាល សហការជាមួយក្រសួង ស.អ.យ និងដាក់ឱ្យប្រើប្រាស់

៣.៤. រៀបចំសម្ភារៈព័ត៌មាន និងទំនាក់ទំនងស្តីពីការបំបែកកុមារពីគ្រួសារដោយមិនចាំបាច់ ដែលត្រូវបញ្ចូលក្នុងគោលនយោបាយភូមិឃុំមានសុវត្ថិភាព

៣.៥. កំណត់អត្តសញ្ញាណកុមារ និងគ្រួសារដែលប្រឈមនឹងហានិភ័យនៃការបំបែកចេញពីគ្រួសារ និងបញ្ជូនបន្តទៅរកសេវាសង្គមផ្សេងៗ ដែលចាំបាច់សម្រាប់គ្រួសារ និងកុមារដែលអនុលោមទៅតាមកម្មវិធីផ្ទេរសាច់ប្រាក់ដែលកំពុងអនុវត្តដោយក្រសួង ស.អ.យ

៣.៦. បន្តអនុវត្តយុទ្ធនាការគ្រួសាររឹងមាំនៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT)

៣.៧. បញ្ចូលបញ្ហានៃអ្នកស្រឡាញ់ភេទដូចគ្នា និងការរើសអើងយេនឌ័រទៅក្នុងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT)

៣.៨. បន្តបណ្តុះបណ្តាលឧបករណ៍ផ្សព្វផ្សាយស្តីពីគ្រួសាររឹងមាំ ជាមួយគ្រួសារគោលដៅនៅតាមសហគមន៍

៣.៩. បន្តអនុវត្តកម្មវិធីការចិញ្ចឹមកូន សម្រាប់ឪពុកម្តាយ និងអ្នកថែទាំងាយរងគ្រោះ ព្រមទាំងសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ ដែលផ្តល់ការថែទាំដល់កុមារសមាហរណកម្មពីកន្លែងថែទាំកុមារ

៣.១០. ផ្សព្វផ្សាយ និងបណ្តុះបណ្តាលសៀវភៅណែនាំអំពីការកែសម្រួល និងពង្រីកបន្ថែមនៃយុទ្ធសាស្ត្រ INSPIRE ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ

៣.១១. ផ្តល់ការគាំទ្រដល់ គ.ក.ន.ក ដោយផ្អែកលើសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់ ក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពជាមួយ CBCPMs ជាពិសេសនៅថ្នាក់ភូមិ ក្រុមកុមារ និងក្រុមឪពុកម្តាយ ដើម្បីលើកកម្ពស់ការយល់ដឹងនៅតាមសហគមន៍

៣.១២. បន្តអនុវត្តសៀវភៅណែនាំសម្រាប់ គ.ក.ន.ក ដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ និងការវិលត្រលប់របស់ពួកគេប្រកបដោយសុវត្ថិភាព

៣.១៣. បណ្តុះបណ្តាល និងផ្សព្វផ្សាយចំណេះដឹង និងសារនានាដល់មន្ត្រីបង្គោល បុគ្គលិកសង្គមនៃមន្ទីរ ស.អ.យ និងមន្ត្រីបង្គោលរាជធានី ខេត្ត និងអ្នកពាក់ព័ន្ធអំពីការរក្សាកុមារក្នុងគ្រួសារ

៣.១៤. ការលើកកម្ពស់ការរក្សាគ្រួសារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារ តាមរយៈអាជ្ញាធរមូលដ្ឋាន ព្រះសង្ឃ និងអ្នកដឹកនាំសាសនាដទៃទៀត

| | |
|---|---|
| **គោលដៅទី៤៖** | ពង្រឹងកិច្ចសហប្រតិបត្តិ ការសម្របសម្រួល និងពិនិត្យតាមដានការងារថែទាំជំនួស និងកិច្ចការពារកុមារ |
| **គោលបំណង៖** | ពង្រឹងកិច្ចសហប្រតិបតិការ និងការសម្របសម្រួលរវាងក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យប្រសើរនូវការថែទាំជំនួស និងកិច្ចការពារកុមាររងគ្រោះ និងងាយរងគ្រោះនៅតាមគ្រួសារ និងសហគមន៍ |
| **លទ្ធផលរំពឹងទុក៖** | កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលលើការងារថែទាំជំនួស និងកិច្ចការពារកុមារក្នុងចំណោមអ្នកពាក់ព័ន្ធ កាន់តែល្អប្រសើរ ស័ក្តសិទ្ធភាព និងប្រសិទ្ធផល |

## សកម្មភាពអនុវត្ត៖

៤.១. បង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីពង្រឹងកិច្ចសហការ ការសម្របសម្រួល និងពិនិត្យតាមដានការអនុវត្តវិស័យថែទាំជំនួសចំពោះកុមារ និងកិច្ចការពារកុមារ

៤.២. បង្កើតផែនទីបង្ហាញជាក់លាក់ ដោយសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីជំរុញ និងសម្របសម្រួលរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងគុណភាពសេវាថែទាំកុមារ ការគ្រប់គ្រងករណី ការសមាហរណកម្ម ការរក្សាកុមារក្នុងគ្រួសារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ផ្សេងទៀត

៤.៣. បង្កើតក្រុមការងារថ្នាក់ខេត្ត ស្រុក ឃុំ សង្កាត់ សម្រាប់ការរក្សាកុមារក្នុងគ្រួសារ (Gatekeeping) និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់

៤.៤. រៀបចំកិច្ចប្រជុំជាប្រចាំនៅថ្នាក់ជាតិ ជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពរួម (មួយដងក្នុងមួយឆមាស) បញ្ហាប្រឈម និងមេរៀនពិសោធន៍ដែលទាក់ទងនឹងបញ្ហាកិច្ចការពារកុមារ

៤.៥. ពង្រឹងយន្តការសម្របសម្រួលក្រុមការងារកិច្ចការពារកុមារនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

៤.៦. បង្កើតសៀវភៅណែនាំនៃសេវាពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅកម្រិតសហគមន៍ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលរួមបញ្ចូលទាំងការអន្តរាគមន៍ និងធនធានដែលមានស្រាប់ រួមទាំង ធ្វើបច្ចុប្បន្នភាពទៀងទាត់

៤.៧. ធ្វើការប្រជុំជាទៀងទាត់នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (យ៉ាងតិចពីរដង ក្នុងមួយឆ្នាំ) ដើម្បីធ្វើបច្ចុប្បន្នអំពីវឌ្ឍនភាព អំពីបញ្ហាប្រឈមដំណោះស្រាយដោយមានការគាំទ្រផ្នែកបច្ចេកទេស ពីក្រសួងសាមី

៤.៨. រៀបចំទស្សនកិច្ចតាមដានត្រួតពិនិត្យរួមគ្នាជាទៀងទាត់រវាងស្ថាប័ន និងអ្នកពាក់ព័ន្ធ ដើម្បីពិនិត្យមើល និងគាំទ្រការអនុវត្តសកម្មភាពនានា ដែលមានផែនការសកម្មភាពនេះ

## ៥. ស្ថាប័ន និងអង្គភាពសម្រាប់អនុវត្តផែនការសកម្មភាព

មាត្រា១៧ នៃអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គនាយកដ្ឋានសេវាសង្គមកិច្ច មានតួនាទីនិងភារកិច្ចផ្តល់សេវាសង្គមកិច្ចទូទៅក្នុងគោលបំណងគាំពារគុណភាពជីវិត សេចក្តីថ្លៃថ្នូរ ការធ្វើឱ្យប្រសើរឡើងនៃស្ថានភាពរស់នៅ បង្ការទប់ស្កាត់បញ្ហាប្រឈមនានារបស់ជនរងគ្រោះ និងងាយរងគ្រោះតាមរយៈសកម្មភាព និងអន្តរាគមន៍កម្រិតបុគ្គល គ្រួសារ សហគមន៍ សេដ្ឋកិច្ចសង្គម និងនយោបាយ។ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច ដែលមាននាយកដ្ឋានកិច្ចការពារកុមារជាសេនាធិការធ្វើការសម្របសម្រួល និងសហការជាមួយអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាពចំណុះក្រសួង ស.អ.យ. មន្ទីរ ស.អ.យ រាជធានី ខេត្ត ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាល រួមទាំងអ្នកពាក់ព័ន្ធដើម្បីអនុវត្តផែនកាសកម្មភាពនេះឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផល ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

## ៦. យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន និងតម្រូវការថវិកា

### ៦.១. យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងលើកគម្រោងចំណាយ និងជំរុញឱ្យស្ថាប័នពាក់ព័ន្ធលើកថវិកាចំណាយសម្រាប់អនុវត្តសកម្មភាព ដើម្បីដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាកម្មវិធីប្រចាំឆ្នាំដើម្បីស្នើសុំថវិកាជាតិ។ ក្រសួងនឹងយកចិត្តទុកដាក់ខ្ពស់លើភាពជាដៃគូនៅក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានាដែលធ្វើសកម្មភាពរបស់ខ្លួនលើការផ្តល់សេវាថែទាំជំនួសចំពោះកុមារ ដើម្បីស្នើសុំការគាំទ្រទាំងថវិកា និងបច្ចេកទេស ដើម្បីអនុវត្តផែនការនេះឱ្យទទួលបានជោគជ័យ។

### ៦.២. តម្រូវការថវិកាសម្រាប់អនុវត្តផែនការសកម្មភាព

ផែនការសកម្មភាពស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៣-២០២៧ នេះ រួមមានការប៉ាន់ប្រមាណថ្លៃចំណាយនៅឧបសម្ព័ន្ធទី១ ដែលនឹងផ្តល់ជាព័ត៌មានមូលដ្ឋានសម្រាប់នីតិវិធីគណនាថ្លៃចំណាយនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីប្រចាំឆ្នាំ និងគម្រោងចំណាយរបស់ដៃគូពាក់ព័ន្ធ។ ក្រសួងនឹងលើកសកម្មភាព និងគម្រោងចំណាយនៅក្នុងថវិកាកម្មវិធីសម្រាប់ថវិកាជាតិ និងស្នើសុំការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។ ការប៉ាន់ប្រមាណថ្លៃចំណាយសម្រាប់សកម្មភាពរយៈពេលវែងប្រាំឆ្នាំ (៥ឆ្នាំ) ជួយគាំទ្រដល់ការអនុវត្តតាមរយៈការជួយកំណត់ពីរបៀបក្នុងការវិភាជន៍ថវិកាដ៏ប្រសើរបំផុត និងចាត់អាទិភាពទៅលើធនធានដែលមានកម្រិត និងការកំណត់រកចន្លោះខ្វះខាតធនធាន ដើម្បីធ្វើការចង្អុលទិសចំពោះសកម្មភាពស្វែងរកមូលនិធិ។ ផែនការសកម្មភាពនេះត្រូវការថវិកាគាំទ្រចំនួនប្រមាណ **២.៨៨៥.៥០០ដុល្លារអាមេរិក** ទាំងថវិការដ្ឋ និងថវិកាដៃគូ ដើម្បីចំណាយតាមគោលដៅ ដូចមានចែងនៅក្នុងតារាងទី១

ខាងក្រោម៖

**តារាងទី១៖ តារាងតម្រូវការថវិកាសម្រាប់អនុវត្តផែនការពីឆ្នាំ២០២៣-២០២៧**

| ល.រ | គោលដៅ | ប៉ាន់ប្រមាណតម្រូវការថវិកា (USD) | | |
|---|---|---|---|---|
| | | សរុបរួម | ថវិការដ្ឋ | ថវិកាដៃគូ |
| ១ | ពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារ | 372,000 | 30% | 70% |
| ២ | ពង្រឹងការគ្រប់គ្រង និងគុណភាពសេវាថែទាំជំនួសចំពោះកុមារ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍ | 1,267,000 | 25% | 75% |
| ៣ | ពង្រឹងកម្មវិធីរក្សាកុមារក្នុងគ្រួសារ និងការទប់ស្កាត់ការបំបែក កុមារចេញពីគ្រួសារដោយមិនចាំបាច់ | 992,000 | 30% | 70% |
| ៤ | ពង្រឹងកិច្ចសហប្រតិបត្តិ ការសម្របសម្រួល និងពិនិត្យតាមដានការងារថែទាំជំនួស និងកិច្ចការពារកុមារ | 254,500 | 35% | 65% |
| **សរុបថវិកាចំណាយ** | | 2,885,500 | 30% | 70% |

## ៧. សេចក្តីសន្និដ្ឋាន

ផែនការនេះ ទាមទារឱ្យមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ និងអគ្គនាយកដ្ឋានសេវាសង្គមកិច្ច អគ្គនាយកដ្ឋាន នាយកដ្ឋានកិច្ចការពារកុមារ នាយកដ្ឋានជំនាញពាក់ព័ន្ធនៃក្រសួង ស.អ.យ មន្ទីរ ស.អ.យ និងអ្នកពាក់ព័ន្ធ។ ការពង្រឹងកិច្ចសហការរវាងម្ចាស់មូលនិធិដែលពាក់ព័ន្ធសំខាន់ៗ រួមទាំងដៃគូអភិវឌ្ឍន៍ក៏មានសារៈសំខាន់ផងដែរ ដើម្បីសម្រេចបាននូវគោលដៅ និងលទ្ធផលរំពឹងទុក។ ការវិភាជន៍ថវិកា និងការផ្តល់បុគ្គលិកបច្ចេកទេសគ្រប់គ្រាន់ពីរាជរដ្ឋាភិបាល គឺជាអាទិភាពដើម្បីធានាថា ការងារថែទាំជំនួសចំពោះកុមារ និងរក្សាកុមារមិនឱ្យបែកចេញគ្រួសារមានដំណើរការល្អ។ លើសពីនេះទៀត ការតាមដានវឌ្ឍនភាពដែលសម្រេចបានក្នុងអំឡុងពេលអនុវត្ត និងការវាយតម្លៃនៅចុងបញ្ចប់លើផែនការសកម្មភាពនៅបំណាច់ឆ្នាំ២០២៧ ទៅតាមសូចនាករសំខាន់ៗដែលបានកំណត់ក្នុងក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដោយរួមបញ្ចូលទាំងការចងក្រងនូវករណីសិក្សា កត្តាប្រឈមនានា និងមេរៀនពិសោធន៍ គឺជាផ្នែកមួយដ៏សំខាន់។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ តារាងម៉ាទ្រីចសកម្មភាព និងសូចនាករ

## ឧបសម្ព័ន្ធទី១៖ តារាងម៉ាទ្រីចសកម្មភាព និងថវិកាគាំទ្រ

### គោលដៅទី១៖ពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារ

| សកម្មភាព | ចំណាយ (USD) | ឆ្នាំ២០២៣-២០២៧ | | | | | អង្គភាព អនុវត្ត | សូចនាករ |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | | |
| ១.១. ពិនិត្យឡើងវិញលើគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឱ្យស្របតាមគោលការណ៍ណែនាំ សម្រាប់ការថែទាំជំនួសចំពោះកុមាររបស់អង្គការសហប្រជាជាតិ និងស្របតាមបរិបទកម្ពុជានាពេលបច្ចុប្បន្ន | 15,000 | x | x | | | | MoSVY | (១)គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារត្រូវបានពិនិត្យកែសម្រួល និងអនុម័ត |
| ១.២. បង្កើត និងអនុវត្តគោលនយោបាយ ឬគោលការណ៍ណែនាំស្តីពីការគាំទ្រដល់គ្រួសារជាលក្ខណៈស្តង់ដារជាតិ ដោយមានផែនការត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់ក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ | 20,000 | | x | X | x | x | MoSVY | (២)គោលនយោបាយ ឬគោលការណ៍ណែនាំស្តីពីការគាំទ្រដល់គ្រួសារ ជាលក្ខណៈស្តង់ដារជាតិត្រូវបានបង្កើត និងអនុវត្ត |
| ១.៣. រៀបចំផែនការករណីសម្រាប់កុមារទាំងអស់ដែលកំពុងស្នាក់នៅក្នុងមណ្ឌល(គ្រប់ករណីទាំងអស់ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងករណី Primero) និងផ្តល់សេវាសមាហរណកម្ម | 20,000 | x | x | | | | MoSVY | (៣) កុមារដែលកំពុងស្នាក់នៅក្នុងមណ្ឌលទាំងអស់ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងករណី Primero និងផ្តល់សេវាសមាហរណកម្ម |
| ១.៤.កែសម្រួលបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ | 25,000 | x | x | | | | MoSVY | (៤)បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល និងសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ត្រូវបានកែសម្រួល និងអនុម័ត |
| ១.៥. កែសម្រួលប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ | 5,000 | x | x | | | | MoSVY | (៥)នីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារត្រូវបានកែសម្រួល និងអនុម័ត |
| ១.៦.ជំរុញការអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | 100,000 | x | x | X | x | x | MoSVY<br>MoI | (៦)រដ្ឋបាលក្រុង ស្រុក ខណ្ឌមានសមត្ថភាពអនុវត្តនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ |
| ១.៧. ពិនិត្យ និងអនុម័តនីតិវិធីអនុវត្តការសុំកូនក្នុងប្រទេសសម្រាប់បន្ថែមជំពូកទី៧ នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ | 10,000 | x | | | | | MoSVY | (៧)នីតិវិធីអនុវត្តការសុំកូនក្នុងប្រទេសត្រូវបានអនុម័ត និងអនុវត្ត |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១.៨. ជំរុញការអនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ និងគោលការណ៍ណែនាំស្តីពីការធ្វើសមារណកម្មកុមារ ការបង្វែរកន្លែងថែទាំ និងការបិទកន្លែងថែទាំកុមារ។ | 50,000 | x | x | X | x | x | MoSVY | (៨) កម្លាំងសេវាសង្គមដែលមានសមត្ថភាពអនុវត្តនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ និងគោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្មកុមារ ការបង្វែរកន្លែងថែទាំ និងការបិទកន្លែងថែទាំកុមារ។ |
| ១.៩. រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ | 12,000 | x | x | | | | MoSVY | (៩)បទដ្ឋានគតិយុត្តពាក់ព័ន្ធដែលមានចែងនៅក្នុងច្បាប់ស្តីពីកិច្ចការពារកុមារត្រូវបានរៀបចំ |
| ១.១០. បន្តរៀបចំសៀវភៅណែនាំស្តីពីនីតិវិធីអនុវត្តមុខងារនៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរងក្រុង ស្រុក ខណ្ឌ | 20,000 | x | x | | | | MoSVY | (១០)សៀវភៅណែនាំស្តីពីនីតិវិធីអនុវត្តមុខងារនៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានបង្កើត និងអនុម័ត |
| ១.១១. បង្កើត និងអនុវត្តសាកល្បងបទដ្ឋានអប្បរមានៃសេវាកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលផ្តោតលើបទដ្ឋាននីតិវិធី ប្រតិបត្តិស្តីពីកិច្ចការពារកុមារ | 25,000 | x | x | | | | MoSVY | (១១)បទដ្ឋានអប្បរមានៃសេវាកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើត និងអនុម័ត |
| ១.១២. បង្កើតបទដ្ឋានអប្បបរមាសម្រាប់ថែទាំ និងកិច្ចការពារកុមារមានពិការភាព | 20,000 | | x | | | | MoSVY | (១២)បទដ្ឋានអប្បបរមាសម្រាប់ថែទាំ និងកិច្ចការពារកុមារមានពិការភាព ត្រូវបានអនុម័ត |
| ១.១៣. បណ្តុះបណ្តាលគុណវុឌ្ឍិនៃអង្គការសុវត្ថិភាពកុមារដល់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល រួមមាន បទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារ និងប្រកាសស្តីពីក្រមសីលធម៌សម្រាប់កិច្ចការពារកុមារ។ល។ | 25,000 | x | x | x | x | x | MoSVY | (១៣) អង្គការចំនួន ៥០ ត្រូវបានបណ្តុះបណ្តាលគុណវុឌ្ឍិនៃអង្គការសុវត្ថិភាពកុមារ |
| ១.១៤.ធ្វើការវាយតម្លៃទៅលើលទ្ធផលនៃការអនុវត្តបទដ្ឋានអប្បបរមានៃសេវាកិច្ចការពារកុមារនិងពង្រីកឱ្យបានគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស | 25,000 | x | x | X | x | x | MoSVY | (១៤)រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានវាយ តម្លៃទៅលើលទ្ធផលនៃការអនុវត្តបទដ្ឋានអប្បបរមានៃសេវាកិច្ចការពារកុមារ |
| **សរុបថវិកាចំណាយ** | 372,000 | | | | | | | |

## គោលដៅទី២៖ពង្រឹងការគ្រប់គ្រង និងគុណភាពសេវាថែទាំជំនួសចំពោះកុមារ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍

| សកម្មភាព | ចំណាយ (USD) | ឆ្នាំ២០២៣-២០២៧ | | | | | អង្គភាពអនុវត្ត | សូចនាករ |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | | |
| ២.១. ពង្រឹងការគ្រប់គ្រងករណីតាមកម្មវិធីសិក្សាសម្រាប់កម្លាំងសេវាសង្គមកិច្ចកម្រិត២ តាមរយៈការពង្រឹងសមត្ថភាពដល់ថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ | 50,000 | x | x | x | x | x | MoSVY | (១) មន្ត្រីរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ មានសមត្ថភាពគ្រប់គ្រងករណី |
| ២.២. ពង្រីកប្រព័ន្ធ Primero ដែលជាឧបករណ៍គ្រប់គ្រងករណីទៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទាំងអស់ ដោយផ្សាភ្ជាប់ទៅនឹងប្រព័ន្ធគ្រប់គ្រងករណីអូស្កា (OSCaR) នឹងឧបករណ៍គ្រប់គ្រងករណីផ្សេងទៀតដែលអង្គការក្រៅរដ្ឋាភិបាលកំពុងប្រើប្រាស់ | 50,000 | x | x | x | x | x | MoSVY | (២) ប្រព័ន្ធ Primero ដែលជាឧបករណ៍គ្រប់គ្រងករណីទៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទាំងអស់ត្រូវបានពង្រីកវិសាលភាព |
| ២.៣.ពង្រឹងការគ្រប់គ្រង និងពង្រឹងប្រសិទ្ធនៃការអនុវត្តប្រព័ន្ធទិន្នន័យ អធិការកិច្ចកន្លែងថែទាំកុមារ និងចាត់វិធានការណ៍ចំពោះកន្លែង ថែទាំកុមារដែលមិនគោរពទៅតាមគោលនយោបាយ និងបទដ្ឋាន គតិយុត្ត | 50,000 | x | x | x | x | x | MoSVY | (៣) កន្លែងថែទាំកុមារទាំងអស់ ត្រូវបានធ្វើអធិការកិច្ចតាមបែបបច្ចេកវិទ្យា |
| ២.៤. បង្កើត និងដំណើរការប្រព័ន្ធត្រួតពិនិត្យសម្រាប់ការគ្រប់គ្រងករណីលើករណីកិច្ចការពារកុមារដល់មន្ត្រីរាជការ នឹងដៃគូអភិវឌ្ឍ ដោយមានការសម្របសម្រួលជាមួយអ្នកជំនាញពីស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដោយរួមទាំងមន្ទីរសង្គមកិច្ចជាអ្នកផ្តល់ការត្រួតពិនិត្យផ្នែកបច្ចេកទេស និងការគាំទ្រ | 30,000 | x | x | x | x | x | MoSVY | (៤)ប្រព័ន្ធត្រួតពិនិត្យសម្រាប់ការគ្រប់គ្រងករណីលើករណីកិច្ចការពារកុមារត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ |
| ២.៥. ធ្វើផែនទីថ្នាក់ជាតិស្តីពីសេវាកម្មគាំទ្រគ្រួសារដែលមានស្រាប់ | 10,000 | x | x | | | | MoSVY | (៥) ផែនទីថ្នាក់ជាតិស្តីពីសេវាកម្មគាំទ្រគ្រួសារ ដែលមានស្រាប់ត្រូវបានធ្វើផែនទី |
| ២.៦.ផ្សារភ្ជាប់ការអនុវត្ត និងធនធានពីកញ្ចប់កិច្ចការគាំពារសង្គមជាមួយនឹងគោលនយោបាយ ឬគោលការណ៍ណែនាំស្តីពីការគាំទ្រដល់គ្រួសារ | 50,000 | x | x | x | x | x | MoSVY<br>NSAF | (៦) គ្រួសារកុមារដែលទទួលបានកញ្ចប់កិច្ចការគាំពារសង្គម |
| ២.៧. ពង្រឹងការតាមដានត្រួតពិនិត្យ និងគាំទ្របច្ចេកទេសចំពោះករណី កុមាររងគ្រោះ និងងាយរងគ្រោះ | 75,000 | x | x | x | x | x | MoSVY | (៧)ករណីកុមាររងគ្រោះនិងងាយរងគ្រោះត្រូវបានតាមដានត្រួតពិនិត្យ និងគាំទ្របច្ចេកទេស |
| ២.៨. ពង្រឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗ ពាក់ព័ន្ធនឹងកិច្ចការពារកុមារ | 50,000 | x | x | x | x | x | MoSVY<br>MoI | (៨) រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានពង្រឹងការអនុវត្តមុខងារកិច្ចការពារកុមារ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២.៩. បង្កើនការបញ្ជូនករណីកិច្ចការពារកុមារពីឃុំ សង្កាត់ ទៅក្រុង ស្រុក ខណ្ឌ និងផ្ដល់សេវាដល់កុមារនិងគ្រួសារដែលរងគ្រោះនិង ងាយរងគ្រោះ | 50,000 | x | x | x | x | x | MoSVY SNA | (៩)កុមារនិងគ្រួសារដែលរងគ្រោះ និងងាយរងគ្រោះដែលទទួលបានសេវា |
| ២.១០. បង្កើនចំនួនបុគ្គលិកសង្គមកិច្ចនៅថ្នាក់ក្រុង ស្រុក ខណ្ឌ តាមរយៈការជ្រើសរើសថ្មី ឬការតែងតាំងមន្ត្រីរាជការដែលមានស្រាប់ | 100,000 | x | x | x | x | x | MoSVY MoI | (១០)ចំនួនបុគ្គលិកសង្គមកិច្ចនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើនចំនួន |
| ២.១១. កំណត់អត្តសញ្ញាណកុមារដែលរងគ្រោះនិងងាយរងគ្រោះ និងតម្រូវការរបស់ពួកគេទៅតាមអាយុ និងភេទ ដើម្បីងាយស្រួលផ្ដល់សេវាគាំទ្រ | 50,000 | x | x | x | x | x | MoI MoSVY | (១១)កុមាររងគ្រោះ និងងាយរងគ្រោះដែលទទួលបានកំណត់អត្តសញ្ញាណ និងទទួលបានសេវា |
| ២.១២. ពង្រឹងការត្រួតពិនិត្យតាមដានការអនុវត្តប្រកាសស្ដីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្ដាយធម៌ព្រមទាំងគោលនយោបាយ និងប្រកាសស្ដីពីនីតិវិធីអនុវត្តគោលនយោបាយ ស្ដីពីការថែទាំជំនួសចំពោះកុមារ | 75,000 | x | x | x | x | x | MoSVY | (១២)អ្នកពាក់ព័ន្ធអនុវត្តនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្ដាយធម៌ និងនីតិវិធីអនុវត្តគោលនយោបាយស្ដីពីការថែទាំជំនួស ចំពោះកុមារត្រូវបានត្រួតពិនិត្យតាមដាន |
| ២.១៣. ផ្ដល់សេវាដើម្បីបង្ការ និងទប់ស្កាត់កុមារដែលងាយរងគ្រោះក្នុងការបែកចេញពីគ្រួសារ | 50,000 | x | x | x | x | x | MoSVY | (១៣)កុមារងាយរងគ្រោះត្រូវបានទប់ស្កាត់ និងផ្ដល់សេវាដើម្បីបង្ការការបែកចេញពីគ្រួសារ |
| ២.១៤. បង្កើត និងអនុវត្តយន្តការត្រួតពិនិត្យសម្រាប់អ្នកថែទាំដែលជាឪពុកម្ដាយធម៌សាច់ញាតិ និងអ្នកផ្ដល់សេវាស្នាក់នៅកូនយោងតាមគោលនយោបាយ និងប្រកាសស្ដីពីនីតិវិធីអនុវត្តគោលនយោបាយ ស្ដីពីការថែទាំជំនួសចំពោះកុមារ | 75,000 | x | x | x | x | x | MoSVY MoI | (១៤)យន្តការត្រួតពិនិត្យសម្រាប់អ្នកថែទាំដែលជាឪពុកម្ដាយធម៌ សាច់ញាតិ និងអ្នកផ្ដល់សេវាស្នាក់នៅកូនត្រូវបានបង្កើត និងអនុវត្ត |
| ២.១៥.ផ្ដល់នូវបណ្ដាញសុវត្ថិភាព (ការគាំទ្រជាសាច់ប្រាក់ និងសេវាគាំពារសង្គមផ្សេងទៀត តាមរយៈរាជរដ្ឋាភិបាល និងការកៀរគរធនធាននានាមកពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល) | 50,000 | x | x | x | x | x | MoSVY MoI | (១៥)បណ្ដាញសុវត្ថិភាពដែលទទួលបានគាំទ្រពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល |
| ២.១៦. ផ្ដល់ការពង្រឹងសេដ្ឋកិច្ចដល់គ្រួសារ ដោយផ្ដោតលើគ្រួសារគោលដៅដែលមានកុមារងាយរងគ្រោះ | 50,000 | x | x | x | x | x | MoSVY | (១៦)គ្រួសារដែលមានកុមារងាយរងគ្រោះដែលទទួលបានការពង្រឹងសេដ្ឋកិច្ចគ្រួសារ |
| ២.១៧. ផ្ដល់ការគាំទ្រឪពុកម្ដាយធម៌ និងសាច់ញាតិ ផ្សារភ្ជាប់ទៅការគាំទ្រការគាំពារសង្គម | 50,000 | x | x | x | x | x | MoSVY | (១៧)ឪពុកម្ដាយធម៌ និងសាច់ញាតិដែលទទួលបានការគាំទ្រការគាំពារសង្គម |
| ២.១៨. ផ្សារភ្ជាប់ប្រព័ន្ធគ្រប់គ្រងករណី Primero និងសេចក្ដីព្រាងអនុក្រឹត្យដើម្បីគាំទ្រដល់ប្រជាជនដែលងាយរងគ្រោះ ដោយរួមបញ្ចូលទាំងការគាំទ្រដល់គ្រួសារដែលមានកុមារងាយរងគ្រោះ | 40,000 | x | x | x | x | x | MoSVY | (១៨)សេចក្ដីព្រាងអនុក្រឹត្យដើម្បីគាំទ្រដល់ប្រជាជន និងកុមារងាយរងគ្រោះដែលបានផ្សារភ្ជាប់ប្រព័ន្ធគ្រប់គ្រងករណី Primero |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២.១៩. កំណត់អត្តសញ្ញាណជនរងគ្រោះ និងបញ្ជូនបន្តទៅរកសេវាសង្គមផ្សេងៗ ដែលចាំបាច់សម្រាប់គ្រួសារ និងកុមារដែលអនុលោមទៅតាមកម្មវិធីផ្ទេរសាច់ប្រាក់ដែលកំពុងអនុវត្តដោយក្រសួង ស.អ.យ | 40,000 | x | x | | | | MoSVY | (១៩)ចំនួនគ្រួសារ និងកុមាររងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណ និងបញ្ចូលទៅក្នុងកម្មវិធី ផ្ទេរសាច់ប្រាក់ |
| ២.២០.ធ្វើការប៉ាន់ប្រមាណស្ថានភាពកុមារដែលកំពុងរស់នៅជាមួយម្ដាយនៅក្នុងពន្ធនាគារ | 10,000 | x | x | | | | MoSVY<br>MoI | (២០)ចំនួនកុមារដែលកំពុងរស់នៅជាមួយម្ដាយនៅក្នុងពន្ធនាគារត្រូវបានប៉ាន់ប្រមាណ |
| ២.២១.ផ្តល់ការគាំទ្រផ្នែកគ្រប់គ្រងករណីដល់កុមារដែលបានកំណត់អត្តសញ្ញាណ រួមទាំងធ្វើសមាហរណកម្មទៅថែទាំក្នុងគ្រួសារ ឬសហគមន៍វិញ បើអាចធ្វើទៅបាន | 50,000 | x | x | x | x | x | MoSVY | (២១) កុមារដែលបានកំណត់អត្តសញ្ញាណរួមទាំង ធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍ដែលទទួលបានគាំទ្រផ្នែកគ្រប់គ្រងករណី |
| ២.២២. សហការជាមួយមណ្ឌលថែទាំកុមារ ដែលមានបំណងធ្វើការបង្វែរកម្មវិធីការថែទាំកុមារក្នុងមណ្ឌលទៅជាការថែទាំតាមបែបសហគមន៍ ឬបិទមណ្ឌលថែទាំ | 25,000 | x | x | x | x | x | MoSVY | (២២)ចំនួនមណ្ឌលថែទាំកុមារមានបំណងធ្វើការបង្វែរកម្មវិធីការថែទាំកុមារក្នុងមណ្ឌលទៅជាការថែទាំតាមបែបសហគមន៍ ឬបិទមណ្ឌលថែទាំត្រូវបានលើកទឹកចិត្ត និងសហការអនុវត្ត |
| ២.២៣. ពង្រឹង និងពង្រីកការអនុវត្តកម្មវិធីការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្ដាយធម៌ និងការសុំកូន (ក្នុងប្រទេស និងក្រៅប្រទេស) រួមទាំងកុមារដែលមានពិការភាព | 50,000 | x | x | x | x | x | MoSVY | (២៣)ចំនួនកុមារ និងកុមារមានពិការភាពដែលទទួលបានសេវាការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្ដាយធម៌ និងការសុំកូន |
| ២.២៤. ត្រៀម និងបន្សាំកុមារអំពីការរស់នៅក្នុងសហគមន៍ មុនពេលចាកចេញពីមណ្ឌលថែទាំ | 25,000 | x | x | x | x | x | MoSVY | (២៤)ចំនួនកុមាររស់នៅក្នុងមណ្ឌលទទួលបានសេវាបន្សាំអំពីការរស់នៅក្នុងសហគមន៍ មុនពេល ចាកចេញពីមណ្ឌលថែទាំ |
| ២.២៥. បន្តតាមដាន និងផ្តល់ការគាំទ្រកុមារដែលចាកចេញពីមណ្ឌលថែទាំ | 25,000 | x | x | x | x | x | MoSVY | (២៥)ចំនួនកុមារដែលចាកចេញពីមណ្ឌលថែទាំដែលទទួលបានការគាំទ្រ និងតាមដានបន្ត |
| ២.២៦. អនុវត្ត និងធ្វើបច្ចុប្បន្នភាពផែនការកិច្ចការពារកុមារក្នុងគ្រាអាសន្នរបស់ក្រសួង | 12,000 | x | | | | | MoSVY | (២៦)ផែនការកិច្ចការពារកុមារក្នុងគ្រាអាសន្នរបស់ក្រសួងត្រូវបានអនុវត្ត និងធ្វើបច្ចុប្បន្នភាព |
| ២.២៧.ផ្តល់ការកសាងសមត្ថភាពដល់អ្នកផ្តល់សេវាដែលពាក់ព័ន្ធទៅនឹងការងារកិច្ចការពារកុមារអំពីស្តង់ដារអប្បបរមានៃការងារកិច្ចការពារកុមារ | 75,000 | x | x | x | x | x | MoSVY | (២៧)ចំនួនអ្នកផ្តល់សេវាកិច្ចការពារកុមារទទួល បានការពង្រឹងសមត្ថភាពអំពីស្តង់ដារអប្បបរមានៃការងារកិច្ចការពារកុមារ |
| **សរុបថវិកាចំណាយ** | 1,267,000 | | | | | | | |

## គោលដៅទី៣៖ពង្រឹងកម្មវិធីរក្សាកុមារក្នុងគ្រួសារ និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់

| សកម្មភាព | ចំណាយ (USD) | ឆ្នាំ២០២៣-២០២៧ | | | | | អង្គភាពអនុវត្ត | សូចនាករ |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | | |
| ៣.១. បង្កើតគណៈកម្មការ ឬក្រុមការងារសម្រាប់ការទប់ស្កាត់ និងការរក្សាគ្រួសារ | 0 | x | | | | | MoSVY | (១)គណៈកម្មការ ឬក្រុមការងារសម្រាប់ការទប់ស្កាត់ និងការរក្សាគ្រួសារត្រូវបានបង្កើតឡើង |
| ៣.២. រៀបចំ និងការផ្សព្វផ្សាយសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់អ្នកស្ម័គ្រចិត្តសហគមន៍ គ.ក.ន.ក និងក្រុមទ្រទ្រង់សុខភាពភូមិ (VHSG) | 60,000 | x | x | x | x | x | MoSVY/MoI | (២)សៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់អ្នកស្ម័គ្រចិត្តសហគមន៍ គ.ក.ន.ក និងក្រុមទ្រទ្រង់សុខភាពភូមិ (VHSG) ត្រូវបង្កើត និងផ្សព្វផ្សាយ |
| ៣.៣. ពិនិត្យឡើងវិញនូវឯកសារបណ្តុះបណ្តាលការថែរក្សាកុមារក្នុងគ្រួសារដែលមានស្រាប់ និងកំពុងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលសហការជាមួយក្រសួង ស.អ.យ និងដាក់ឱ្យប្រើប្រាស់ | 5,000 | x | | | | | MoSVY | (៣)សៀវភៅបណ្តុះបណ្តាលការថែរក្សាកុមារក្នុងគ្រួសារត្រូវបានបង្កើត និងអនុម័ត |
| ៣.៤. រៀបចំសម្ភារៈព័ត៌មាន និងទំនាក់ទំនងស្តីពីការបំបែកកុមារពីគ្រួសារដោយមិនចាំបាច់ ដែលត្រូវបញ្ចូលក្នុងគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព | 5,000 | | x | | | | MoSVY/MoI | (៤)សម្ភារៈព័ត៌មាន និងទំនាក់ទំនងស្តីពីការបំបែកកុមារពីគ្រួសារដោយមិនចាំបាច់ ដែលត្រូវបញ្ចូលក្នុងគោលនយោបាយភូមិឃុំមានសុវត្ថិភាព |
| ៣.៥. កំណត់អត្តសញ្ញាណកុមារ និងគ្រួសារដែលប្រឈមនឹងហានិភ័យនៃការបំបែកចេញពីគ្រួសារ និងបញ្ជូនបន្តទៅរកសេវាសង្គមផ្សេងៗ ដែលចាំបាច់សម្រាប់គ្រួសារ និងកុមារដែលអនុលោមទៅតាមកម្មវិធីផ្ទេរសាច់ប្រាក់ដែលកំពុងអនុវត្តដោយក្រសួង ស.អ.យ | 100,000 | x | x | x | x | x | MoSVY/MoI | (៥)កុមារ និងគ្រួសារដែលប្រឈមហានិភ័យត្រូវបានបញ្ជូនបន្តទៅរកសេវាសង្គមផ្សេងៗ |
| ៣.៦.បន្តអនុវត្តយុទ្ធនាការគ្រួសាររឹងមាំនៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT) | 200,000 | x | x | x | x | x | MoSVY MoWA | (៦)យុទ្ធនាការគ្រួសាររឹងមាំនៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT) ដែលត្រូវបានអនុវត្តបន្ត |
| ៣.៧.បញ្ចូលបញ្ហានៃអ្នកស្រឡាញ់ភេទដូចគ្នា និងការរើសអើងយេនឌ័រទៅក្នុងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT) | 12,000 | x | x | | | | MoSVY MoWA | (៧) យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT) ដែលត្រូវបានបញ្ចូលបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា និងការរើស-អើងយេនឌ័រ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣.៨. បន្តបណ្តុះបណ្តាលឧបករណ៍ផ្សព្វផ្សាយស្តីពីគ្រួសាររឹងមាំ ជាមួយគ្រួសារគោលដៅនៅតាមសហគមន៍ | 120,000 | x | x | x | x | x | MoSVY MoWA | (៨)គ្រួសារគោលដៅនៅតាមសហគមន៍មានចំណេះដឹងអំពីគ្រួសាររឹងមាំ |
| ៣.៩. កម្មវិធីការចិញ្ចឹមកូន សម្រាប់ឪពុកម្តាយ និងអ្នកថែទាំងាយរងគ្រោះ ព្រមទាំងសម្រាប់ឪពុកម្តាយ និង អ្នកថែទាំ ដែលផ្តល់ការថែទាំដល់កុមារសមាហរណកម្មពីកន្លែងថែទាំកុមារ | 50,000 | x | x | x | x | x | MoSVY MoWA | (៩)ឧបករណ៍កម្រិតទី៣ នៃការចិញ្ចឹមកូនបែបវិជ្ជមានដែលត្រូវបានអនុវត្ត |
| ៣.១០. ផ្សព្វផ្សាយ និងបណ្តុះបណ្តាលសៀវភៅណែនាំអំពីការកែសម្រួល និងពង្រីកបន្ថែមនៃយុទ្ធសាស្ត្រ INSPIRE ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ | 150,000 | x | x | x | x | x | MoSVY MoWA | (១០)យុទ្ធសាស្ត្រ INSPIRE ដើម្បីបញ្ចប់អំពើហិង្សាលើកុមារត្រូវបានផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ក្រុមគោលដៅ |
| ៣.១១. ផ្តល់ការគាំទ្រដល់ គ.ក.ន.ក ដោយផ្អែកលើសៀវភៅណែនាំស្តីពី ការការពារកុមារសម្រាប់ឃុំ សង្កាត់ ក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពជាមួយ CBCPMs ជាពិសេសនៅថ្នាក់ភូមិ ក្រុមកុមារ និងក្រុមឪពុកម្តាយ ដើម្បីលើកកម្ពស់ការយល់ដឹងនៅតាមសហគមន៍ | 100,000 | x | x | x | x | x | | (១១) ចំនួន គ.ក.ន.ក ដែលដែលមានសមត្ថភាពអនុវត្តការងារ CBCPMs នៅថ្នាក់ភូមិ ក្រុមកុមារ និងក្រុមឪពុកម្តាយ ដើម្បីលើកកម្ពស់ការយល់ដឹងនៅតាមសហគមន៍ |
| ៣.១២. បន្តអនុវត្តសៀវភៅណែនាំសម្រាប់ គ.ក.ន.ក ដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ និងការវិលត្រលប់របស់ពួកគេប្រកបដោយសុវត្ថិភាព | 25,000 | x | x | x | x | x | MoI/MoSVY | (១២) គ.ក.ន.ក ត្រូវបានបណ្តុះបណ្តាលអំពីការណែនាំ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ និងការវិលត្រលប់របស់ពួកគេប្រកបដោយសុវត្ថិភាព |
| ៣.១៣. បណ្តុះបណ្តាល និងផ្សព្វផ្សាយចំណេះដឹង និងសារនានាដល់មន្ត្រីបង្គោលបុគ្គលិកសង្គមនៃមន្ទីរ ស.អ.យ និងមន្ត្រីបង្គោលរាជធានី ខេត្ត និងអ្នកពាក់ព័ន្ធអំពីការរក្សាកុមារក្នុងគ្រួសារ (Gatekeeping) | 50,000 | x | x | x | x | x | MoSVY | (១៣)មន្ត្រីបង្គោល បុគ្គលិកសង្គមនៃមន្ទីរ ស.អ.យ និងមន្ត្រីបង្គោលរាជធានី ខេត្ត និងអ្នកពាក់ព័ន្ធចំនួន ៥០០នាក់ បានទទួលការបណ្តុះបណ្តាលអំពីការរក្សាកុមារក្នុងគ្រួសារ (Gatekeeping) |
| ៣.១៤. ការលើកកម្ពស់ការរក្សាគ្រួសារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារ តាមរយៈព្រះសង្ឃ និងអ្នកដឹកនាំសាសនាដទៃ ទៀត | 25,000 | x | x | x | x | x | MCR/ MoSVY | (១៤)ព្រះសង្ឃ និងអ្នកដឹកនាំសាសនាដទៃទៀតបានផ្សព្វផ្សាយអំពីការលើកកម្ពស់ការរក្សាគ្រួសារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារ |
| **សរុបថវិកាចំណាយ** | 992,000 | | | | | | | |

### គោលដៅទី៤៖ ពង្រឹងកិច្ចសហប្រតិបត្តិ ការសម្របសម្រួល និងពិនិត្យតាមដានការងារថែទាំជំនួស និងកិច្ចការពារកុមារ

| សកម្មភាព | ចំណាយ (USD) | ឆ្នាំ២០២៣-២០២៧ | | | | | ស្ថាប័នអនុវត្ត | សូចនាករ |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | | |
| ៤.១.បង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីពង្រឹងកិច្ចសហការ ការសម្របសម្រួល និងពិនិត្យតាមដានការអនុវត្តវិស័យថែទាំជំនួសចំពោះ កុមារ និងកិច្ចការពារកុមារ | 25,000 | x | x | x | x | x | MoSVY | (១)ក្រុមការងារថ្នាក់ជាតិដើម្បីពង្រឹងកិច្ចសហការ ការសម្របសម្រួល និងពិនិត្យតាម ដានការអនុវត្តវិស័យថែទាំជំនួសចំពោះកុមារ និងកិច្ចការពារកុមារត្រូវបានបង្កើត |
| ៤.២. បង្កើតផែនទីបង្ហាញជាក់លាក់ ដោយសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីជំរុញ និងសម្របសម្រួលរដ្ឋបាល ថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងគុណភាពសេវាថែទាំកុមារ ការគ្រប់គ្រងករណី ការសមាហរណកម្ម ការរក្សាកុមារក្នុងគ្រួសារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត | 7,500 | x | x | x | x | x | Office of SASW | (២)ផែនទីបង្ហាញជាក់លាក់នៃការបង្កើតផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារត្រូវបានបង្កើត |
| ៤.៣. បង្កើតក្រុមការងារថ្នាក់ខេត្ត ស្រុក ឃុំ សង្កាត់ សម្រាប់ការរក្សាកុមារក្នុងគ្រួសារ (Gatekeeping) និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ | 0 | x | x | | | | MoSVY/MoI | (៣)ក្រុមការងារថ្នាក់ខេត្ត ស្រុក ឃុំ សង្កាត់ សម្រាប់ការរក្សាកុមារក្នុងគ្រួសារ (Gatekeeping) និងទប់ស្កាត់ការបំបែកកុមារចេញ ពីគ្រួសារដោយមិនចាំបាច់ត្រូវបានបង្កើតឡើង |
| ៤.៤. រៀបចំប្រជុំជាប្រចាំនៅថ្នាក់ជាតិ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពរួម (មួយដងក្នុងមួយឆមាស) បញ្ហាប្រឈមនិងមេរៀនពិសោធន៍ដែលទាក់ទងនឹងបញ្ហាកិច្ចការពារកុមារ | 25,000 | x | x | x | x | x | MoSVY MoI | (៤)ចំនួនកិច្ចប្រជុំនៅថ្នាក់ជាតិដើម្បីពិភាក្សាអំពីវឌ្ឍនភាពកិច្ចការពារកុមារត្រូវបានរៀបចំ ប្រចាំឆ្នាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤.៥. ពង្រឹងយន្តការសម្របសម្រួលក្រុមការងារកិច្ចការពារកុមារនៅថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | 135,000 | x | x | x | x | x | Provincial Governors, District Governors | (៥)យន្តការសម្របសម្រួលក្រុមការងារកិច្ចការពារកុមារនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលត្រូវបង្កើត និងពង្រឹងសមត្ថភាព |
| ៤.៦.បង្កើតសៀវភៅមគ្គុទេសន៍ នៃសេវាពាក់ព័ន្ធនឹងកិច្ចការពារកុមារ នៅកម្រិតសហគមន៍ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលរួមបញ្ចូលទាំងការអន្តរាគមន៍ និងធនធានដែលមានស្រាប់ រួមទាំងធ្វើបច្ចុប្បន្នភាពទៀងទាត់ | 12,000 | | x | | | | MoSVY MoI | (៦)សៀវភៅមគ្គុទេសន៍ នៃសេវាពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅកម្រិតសហគមន៍ដែលត្រូវបានបង្កើត និងអនុម័ត |
| ៤.៧. ធ្វើការប្រជុំជាទៀងទាត់នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (យ៉ាងតិចពីរដងក្នុងមួយឆ្នាំ) ដើម្បីធ្វើបច្ចុប្បន្នអំពីវឌ្ឍនភាពអំពីបញ្ហាប្រឈមដំណោះស្រាយ ដោយមានការគាំទ្រផ្នែកបច្ចេកទេស ពីក្រសួងសាមី | 25,000 | x | x | x | x | x | Provincial Governors | (៧)ចំនួនកិច្ចប្រជុំកម្រិតបច្ចេកទេសនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ និងការគាំទ្រពីក្រសួងសាមី |
| ៤.៨.រៀបចំទស្សនកិច្ចតាមដានត្រួតពិនិត្យរួមគ្នាជាទៀងទាត់រវាងស្ថាប័ន និងអ្នកពាក់ព័ន្ធដើម្បីពិនិត្យមើល និងគាំទ្រការអនុវត្ត សកម្មភាពនានា ដែលមានផែនការសកម្មភាពនេះ | 25,000 | x | x | x | x | x | MoSVY/MoI /UNICEF | (៨) ចំនួនទស្សនកិច្ចតាមដានត្រួតពិនិត្យ រួមគ្នាជាទៀងទាត់រវាងស្ថាប័ន និងអ្នកពាក់ព័ន្ធ ដើម្បីពិនិត្យមើល និងគាំទ្រការ អនុវត្តសកម្មភាពនានា |
| **សរុបថវិកាចំណាយ** | 254,500 | | | | | | | |

គាំទ្រដោយ

គាំទ្រដោយ

USAID
ជំនួយពីពលរដ្ឋអាមេរិក

unicef
for every child